សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# និដ្ឋភាពគតិយុត្តនៃសន្តតិកម្ម ៖ ករណីប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ហេង ច័ន្ទសុត្រា**
**ឯម មុន្នីរ័ត្ន**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ហាប់ ផល្លី**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០
ឆ្នាំសរសេរសារណា ២០១៤

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំដែលជានិស្សិតក្រុមដែលមានឈ្មោះ **ហេង ច័ន្ទសុត្រា** និង**ឯម មុន្នីរ័ត្ន** ដែលជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

សូមគោរពប្រតិបត្តិនិងសូមសំដែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ ៖
លោក **ឪពុក អ្នកម្ដាយ** ដែលអ្នកមានគុណទាំងទ្វេដែលបានផ្ដល់កំណើតដល់កូន និងបានខិតខំអស់ទាំងកំលាំងកាយចិត្តដោយពុំខ្លាចនឿយហត់ ក្នុងការចិញ្ចឹមបីបាច់ថែរក្សារអប់រំ ទូន្មានប្រៀនប្រដៅឲ្យយើងខ្ញុំខិតខំរៀនសូត្រ និងប្រព្រឹតតែអំពើល្អ។ មិនតែប៉ុណ្ណោះ លោកឪពុក អ្នកម្ដាយបានធ្វើការឧបត្ថម្ភគាំទ្រយើងខ្ញុំទាំងផ្នែកស្មារតី ធនធាន និងសម្ភារតាំងពីយើងខ្ញុំនៅតូចរហូតពេញវ័យ ហើយថែមទាំងជំរុញឲ្យយើងខ្ញុំមានឧកាសចូលសិក្សាក្រេបចិញ្ចាក់ចំណេះដឹងតាំងពីកម្រិតមូលដ្ឋានរហូតមកដល់ពេលបច្ចុប្បន្ននេះ។

យើងខ្ញុំក៏សូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះ ៖
ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋ-កិច្ចដែលបានផ្ដល់ឪកាសឲ្យយើងខ្ញុំពង្រីកនូវចំនេះដឹង និងបង្កើតនូវជំនាញតាមរយៈការចងក្រងកិច្ចការស្រាវជ្រាវនេះឡើង។

ជាពិសេសលោកសាស្ត្រាចារ្យ **ហាប់ ផល្លី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ការប្រឹងប្រែងមិនក្លាចនឿយហត់ក្នុងការចង្អុលបង្ហាញនូវការណែនាំ និងការកែប្រែកំហុសឆ្គងរបស់យើងខ្ញុំដើម្បីធានានូវសមិទ្ធផលមួយដែលប្រកបដោយគុណភាព ។

លោក និងលោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្ហាត់បង្រៀនអប់រំ ណែនាំ ផ្ដល់ឪវាទល្អៗ និងបទពិសោធន៍ល្អៗគ្រប់បែបយ៉ាងដល់យើងខ្ញុំតាំងពីថ្នាក់មូលដ្ឋានរហូតមកដល់ពេលបច្ចុប្បន្ននេះ ។

សិស្សច្បង និងមិត្តនិស្សិត ដែលបានណែនាំពីការស្រាវជ្រាវឯកសារ និងបានជួយរកឯកសារដល់យើងខ្ញុំទាំងអស់គ្នា ព្រមទាំងបានជួយពិនិត្យលើអក្ខរាវិរុទ្ធ កែសម្រួលលើកំហុសឆ្គងថែមទៀតដែលជាកំលាំងចិត្តជំរុញឲ្យយើងខ្ញុំខិតខំបន្តការស្រាវជ្រាវនេះរហូតដល់ការស្រាវជ្រាវនេះបានសម្រេច ។

យើងខ្ញុំទាំងអស់គ្នាសូមគោរពជូនពរ និងសូមលើកហត្ថាទាំងទ្វេបួងសួងដល់ទេវតា ដែលតាមថែរក្សាព្រះរាជាណាចក្រកម្ពុជាទាំងឡាយសូមជួយថែរក្សា លោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាស្ត្រាចារ្យ លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកដែលបានជួយទំនុកបំរុងក្នុងកិច្ចការស្រាវជ្រាវនេះឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ និងសូមឲ្យទទួលជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ខ្ញុំបាទឈ្មោះ ហេង ច័ន្ទសុត្រា និងនាងខ្ញុំឈ្មោះ ឯម មុន្នីរ័ត្ន ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៤ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមាន កិត្តិយស និងនៅក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងការតាក់តែង និងចងក្រងប្រធានបទមួយនៃសារណាបញ្ចប់ការសិក្សាស្តីពី "ទិដ្ឋភាពគតិយុត្តនៃសន្តតិកម្មៈ ករណីប្រទេសកម្ពុជា" ដែលទាក់ទងនឹង ការសិក្សាលើមុខវិជ្ជា នីតិរដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី និងនីតិបេតិកភណ្ឌគ្រួសារ ដែលបានសិក្សា កន្លងមកដើម្បីយកទ្រឹស្តីនៃមុខវិជ្ជាទាំងអស់នេះមកធ្វើការអនុវត្តផ្ទាល់។

យើងខ្ញុំបានធ្វើការបែងចែកមាតិកាជាផ្នែកតូចៗ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្រាវជ្រាវស្វែងរកនូវឯកសារបន្ថែម ក៏ដូចជាងាយស្រួលក្នុងការពន្យល់ និងលើកយកមកពិភាក្សាក្នុងគោលបំណងចងក្រងឲ្យបាននូវស្នាដៃដ៏ល្អមួយ។ យើងខ្ញុំបានប្រមូលផ្តុំនូវឯកសារស្រាវជ្រាវដែល យើងខ្ញុំបានចុះទៅតាមស្ថាប័នរដ្ឋ ដោយឆ្លងកាត់ការពិនិត្យ និងកែតម្រូវ ជាពិសេសយើងខ្ញុំបានសុំធ្វើ បទសម្ភាសពីលោកមេធាវីអំពីការអនុវត្តជាក់ស្តែង និងរាល់បញ្ហាប្រឈម ដើម្បីលើកយកមកធ្វើការពិភាក្សាក្នុងសៀវភៅមួយក្បាលនេះ។ ជាលទ្ធផលយើងខ្ញុំទទួលបាននូវស្នាដៃមួយនេះដើម្បីប្រគល់ជូនការិយាល័យស្រាវជ្រាវបានទាន់ពេលវេលាដែលបានកំណត់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងការដាក់ពិន្ទុពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យដែលជាគណៈកម្មាការ។

ជាមួយគ្នានេះផងដែរ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ស្នាដៃមួយនេះអាចចូលរួមចំណែកធ្វើឲ្យជនរួមជាតិទាំងឡាយមានការយល់ដឹងបន្ថែមអំពីសន្តតិកម្ម ក៏ដូចជាផ្នែកច្បាប់ ជាពិសេសដើម្បីឲ្យនិស្សិតខ្មែរ និងប្រជាពលរដ្ឋគ្រប់ស្រទាប់បានយល់អំពីផ្នែកនេះកាន់តែស៊ីជម្រៅ និងអាចយកមកធ្វើការអនុវត្តនៅក្នុងសង្គមរស់នៅផងដែរ។

ជាចុងក្រោយនេះ ទោះបីជាយើងខ្ញុំបានខិតខំប្រឹងប្រែង និងព្យាយាមពិនិត្យយ៉ាងណាក៏ដោយ ល៏កិច្ចការមួយនេះពិតជាអាចមាននូវកំហុសឆ្គងខ្លះៗ ទាំងចេតនាក្តី ឬ អចេតនាក្តី នៅត្រង់ចំណុចណាមួយជាមិនខាន។ អាស្រ័យហេតុនេះហើយ ក្នុងនាមយើងខ្ញុំជាអ្នកតាក់តែង សូមធ្វើការអភ័យទោសជា មុននូវរាល់កំហុសឆ្គង និងការខ្វះខាតក៏ដូចជាទទួលការរិះគន់ផ្សេងៗ ក្នុងគោលបំណងស្ថាបនាស្នាដៃមួយនេះឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើងបន្ថែមទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីថ្លែងអំណរគុណ** ........ i
**អារម្ភកថា** ........ ii
**មាតិកា** ........ iii
**បញ្ជីតារាង និងបញ្ជីរូប** ........ v
**សេចក្តីផ្តើម** ........ ១
**ជំពូកទី ១ សញ្ញាណទូទៅនៃសន្តតិកម្ម** ........ ៣
**១.១ ការចាប់ផ្តើមសន្តតិកម្ម** ........ ៣
១.១.១ មូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម ........ ៣
១.១.២ ទីកន្លែងចាប់ផ្តើមសន្តតិកម្ម ........ ៤
**១.២ ប្រភេទនៃសន្តតិកម្ម** ........ ៥
១.២.១ សន្តតិកម្មតាមច្បាប់ ........ ៥
១.២.១.១ សន្តតិជន ........ ៥
១.២.១.២ ការសម្រួលចំណែកមតិក ........ ១៣
១.២.២ សន្តតិកម្មតាមមតកសាសន៍ ........ ១៤
១.២.២.១ សមត្ថភាពក្នុងការធ្វើមតកសាសន៍ ........ ១៥
១.២.២.២ ទម្រង់នៃមតកសាសន៍ និងមតកសាសន៍សម្រាប់ជនស្ថិតក្នុងករណីពិសេស... ១៥
**១.៣ ភាគបម្រុង** ........ ២០
១.៣.១ អ្នកមានសិទ្ធិលើភាគបម្រុង ........ ២១
១.៣.២ ការកាត់បន្ថយភាគបម្រុង ........ ២១
**១.៤ ការយល់ព្រម និងការបោះបង់សន្តតិកម្ម** ........ ២៣
១.៤.១ ការយល់ព្រមទាំងស្រុង និងដោយកម្រិត ........ ២៣
១.៤.២ ការបោះបង់សន្តតិកម្ម ........ ២៤
**ជំពូកទី ២ ការអនុវត្តនៃសន្តតិកម្ម** ........ ២៦
២.១ ការបែងចែកតាមការស្រុះស្រួលគ្នា ........ ២៦
២.២ ការបែងចែកតាមផ្លូវតុលាការ ........ ២៨
**ជំពូកទី ៣ បញ្ហាប្រឈមនៃសន្តតិកម្ម** ........ ៣១
៣.១ នីតិវិធីនៃការបែងចែកសន្តតិកម្ម ........ ៣១

៣.២ ដីដែលមិនទាន់បានចុះបញ្ជី............................................................................ ៣២
**សន្និដ្ឋាន** ......................................................................................................... ៣៣
**អនុសាសន៍** ......................................................................................................... ៣៤
**គន្ថនិទ្ទេស** ......................................................................................................... ៣៥

# បញ្ជីរូប និងបញ្ជីតារាង

រូបភាពទី ១ លំដាប់សន្តតិជន, ទំព័រ ១០។

តារាងទី ១ ប្រភេទនៃលិខិតមតកសាសន៍, ទំព័រ១៨។

តារាងទី២ ការប្រៀបធៀបការយល់ព្រមទាំងស្រុង ការយល់ព្រមដោយកម្រិត និងការបោះបង់,ទំព័រ ២៥។

តារាងទី៣ តួលេខសំណុំរឿងសុំបែងចែកមត៌ក និងសុំលែងលះ, ទំព័រ២៩។

# សេចក្ដីផ្ដើម

ប្រទេសកម្ពុជាបានអនុវត្តសន្តតិកម្មចាប់តាំងពីសម័យបុរាណមកម្ល៉េះ។ ការគ្រប់គ្រង ការបែងចែកមតិក ប្រជាជនកម្ពុជាបានអនុវត្តជាលក្ខណៈបែបប្រពៃណី ដោយនៅសម័យអង្គរស្ត្រីមាន សិទ្ធិធំជាងបុរស ដូចនេះស្ត្រីមានសិទ្ធិចាត់ចែងទ្រព្យសម្បត្តិ រីឯការបែងចែកទ្រព្យសម្បត្តិវិញត្រូវធ្វើតាមខ្សែស្រឡាយខាងស្រីជាដរាប ដោយចាប់យកខ្សែស្រឡាយខាងម្ដាយជាធំ។[1] បច្ចុប្បន្នការអនុវត្តសន្តតិកម្មមានលក្ខណៈផ្ទុយស្រលះពីការបែងចែកមតិកពីសម័យអង្គរ។ ម្យ៉ាងវិញទៀតដោយ សារតែប្រទេសកម្ពុជាទទួលការគ្រប់គ្រងពីបារាំង ការអនុវត្តសន្តតិកម្មបានកែប្រែពីមួយសម័យកាលទៅមួយសម័យកាល។ នៅលើពិភពលោករបបសន្តតិកម្មមានគោលការណ៍ពីរប្រភេទជាចម្បង គឺគោលការណ៍ទទួលបន្តដោយស្វ័យប្រវិត្ត និងគោលការណ៍ជម្រះបញ្ជី។ គោលការណ៍ទទួលបន្ត-ដោយស្វ័យប្រវិត្ត មានន័យថាសន្តតិជនត្រូវទទួលស្នងមតិកតែម្ដង មុននឹងធ្វើការបែងចែក ឬ សងបំណុល។ រីឯគោលការណ៍ជម្រះបញ្ជីគឺ ជាការជម្រះសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ហើយសន្តតិជនអាចស្នងមតិកបានតែក្នុងករណីនៅសល់ទ្រព្យសកម្មតែប៉ុណ្ណោះ។ ប្រទេសកម្ពុជាបានជ្រើសរើសយកគោលការណ៍ជម្រះបញ្ជី ដែលជាគោលការណ៍ការពារសិទ្ធិរបស់សន្តតិជនក៏ដូចជាតតិយជនផងដែរ។

ទោះបីជាមានរបបសន្តតិកម្មហើយក្ដី ក៏ជំលោះទាក់ទងនឹងទំនាស់ផលប្រយោជន៍នៅតែកើតមានឡើងគួរឲ្យកត់សម្គាល់។ ទំនាស់ផលប្រយោជន៍កើតឡើងដោយសារតែការបែងចែកទ្រព្យសម្បត្តិរវាងសហសន្តតិជនមិនមានលក្ខណៈសមភាពដែលអាចបណ្ដាលឲ្យមានទំនាស់រវាងសហ-សន្តតិជនកើតមានឡើង នឹងអាចឈានដល់ការដាក់ពាក្យបណ្ដឹងទៅតុលាការថែមទៀតផង។ ម្យ៉ាងវិញទៀតដោយសារតែទ្រព្យខ្លះមិនបានចុះបញ្ជីដែលនាំឲ្យការបែងចែកទ្រព្យសម្បត្តិមានលក្ខ-ណៈស្មុគស្មាញ និងមានឧបសគ្គច្រើន។

គោលបំណងរបស់សារណានេះផ្ដោតសំខាន់ទៅលើការសន្តតិជន ការយល់ព្រម និងការបោះបង់សន្តតិកម្ម ការបែងចែកសន្តតិកម្ម ការអនុវត្តសន្តតិកម្ម ជាពិសេសរាល់បញ្ហាប្រឈមដែលកើតមានឡើងក្នុងសង្គមកម្ពុជាដែលពាក់ព័ន្ធទៅនឹងការបែងចែកទ្រព្យរបស់មតកជន។ តាមរយៈសារណានេះផងដែរបានឆ្លុះបញ្ចាំងឲ្យឃើញនូវសិទ្ធិ និងកាតព្វកិច្ចរបស់សន្តតិជនទៅលើសន្តតិកម្ម

[1] ត្រឹងងា, *ប្រវត្តិសាស្ត្រខ្មែរ,* បោះពុម្ពលើកទី៣, (ភ្នំពេញ៖ បណ្ណាគារ IBC, ឆ្នាំ២០០៩),ទំព័រ ២៨។

ក៏ដូចជាការការពារសិទ្ធិរបស់តតិយជន នៅក្នុងរឿងបំណុលក្រោយពេលមរណៈភាពរបស់មតកជន។ ជាពិសេសពាក់ព័ន្ធនឹងការផ្តល់សិទ្ធិឲ្យសន្តតិជនធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្មទៅតាមឆន្ទៈរបស់សន្តតិជន។

ការខិតខំប្រឹងប្រែងប្រមូលឯកសារដែលពាក់ព័ន្ធនឹងសន្តតិកម្ម និងធ្វើការស្រាវជ្រាវ បន្ថែមដើម្បីទទួលបានចំណេះដឹងជាច្រើនដើម្បីចងក្រងសារណាមួយនេះឡើង។ ដោយបានចុះទៅសាលាដំបូងរាជធានីភ្នំពេញដើម្បីស្រាវជ្រាវឯកសារ និងពិនិត្យសំណុំរបាយការណ៍ការងារក្នុងមួយឆ្នាំៗរបស់សាលាដំបូងដែលពាក់ព័ន្ធនឹងការសុំបែងចែកទ្រព្យសម្បត្តិ ថាតើមានពត៌មានអ្វីខ្លះដែលនាំឲ្យមានការប្តឹងផ្តល់តាមផ្លូវតុលាការ។ បន្ថែមពីនេះទៅទៀតការសម្ភាស លោកមេធាវី ដើម្បីសុំជាគំនិតយោបល់រាល់បញ្ហាប្រឈមដែលកើតមានឡើងដោយសារតែសន្តតិកម្មនេះ។

តើទ្រព្យដែលមានបណ្តាំមតិកពិតជាមិនមានផលវិបាកដល់ការបែងចែកទ្រព្យសម្បត្តិទេរឺ? ហើយចំពោះមតិកដែលមិនបានបន្សល់ទុកនូវមតកសាសន៍មានបញ្ហាអ្វីខ្លះ? តើក្របខណ្ឌគតិយុត្ត ឬ បទប្បញ្ញត្តិពាក់ព័ន្ធអាចជួយកាត់បន្ថយនូវបញ្ហាទាំងអស់នោះយ៉ាងដូចម្តេច?

សារណានេះត្រូវបានបែងចែកជាបីជំពូកធំៗ។ ដែលជំពូកទី១ បង្ហាញអំពីសញ្ញាណទូទៅនៃសន្តតិកម្មដែលក្នុងនោះមាន មូលនៃសន្តតិកម្ម ប្រភេទសន្តតិកម្ម។ ចំណែកឯជំពូកទី២ពិភាក្សាអំពីការអនុវត្តសន្តតិកម្ម។ រីឯជំពូកចុងក្រោយនិយាយអំពី បញ្ហាប្រឈមនៃសន្តតិកម្ម។

# ជំពូកទី ១ សញ្ញាណទូទៅនៃសន្តតិកម្ម

## ១.១ ការចាប់ផ្តើមសន្តតិកម្ម

ការយល់ដឹងអំពីអត្ថន័យសន្តតិកម្មវាជាចំណុចសំខាន់នៃការពិភាក្សា សន្តតិកម្មគឺ ជាការផ្ទេរសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬ ច្រើននាក់ តាមឆន្ទៈ ឬ តាមច្បាប់។[2] មានន័យថា បុគ្គលដែលទទួលមរណភាព ឬ អាចហៅថាមតកជន អាចផ្ទេរសិទ្ធិរបស់គាត់ តាមរយៈបណ្តាំ ឬ អាចហៅម្យ៉ាងទៀតថា មតកសាសន៍ ទៅឲ្យសាច់ញាតិរបស់គាត់ដែលនៅរស់។ ប៉ុន្តែការផ្ទេរសិទ្ធិនោះ ត្រូវគោរពទៅតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់។ ចំណែកករណីយកិច្ចរបស់សន្តតិជន ត្រូវទទួលបន្តនូវ សិទ្ធិ និងករណីយកិច្ចទាំងអស់របស់មតកជន។ ប៉ុន្តែប្រសិនបើមតកជននោះបានបន្សល់នូវកាតព្វកិច្ចច្រើនពេក សន្តតិជនដែលទទួលបន្តនូវកាតព្វកិច្ចទាំងនោះ នឹងត្រូវធ្វើឲ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ដោយសារសន្តតិកម្ម។ នេះជាហេតុដែលនាំឲ្យ ច្បាប់កម្ពុជាបង្កើតឲ្យមានរបបបោះបង់នូវសន្តតិកម្ម ឬការយល់ព្រមដោយមានកម្រិត ដើម្បីជៀសវាងនូវស្ថានភាពនោះ។

### ១.១.១ មូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម

គួរកត់សម្គាល់ផងដែរថាសន្តតិកម្មចាប់ផ្តើមឡើងដោយសារមូលហេតុនៃការបាត់ខ្លួន និងមរណភាពសន្តតិកម្ម ត្រូវចាប់ផ្តើមឡើងដោយសារមានមរណភាពរបស់មតកជន ហើយត្រូវស្វែងរកអ្នកដែលមានសិទ្ធិដើម្បីទទួលបន្តនូវទ្រព្យសម្បត្តិនោះរបស់មតកជន។ ចំណុចនេះមានន័យថា គេមិនទទួលស្គាល់សន្តតិកម្មពេលដែលមតកជននៅរស់ទេ។ សន្តតិកម្មអាចចាប់ផ្តើមបានតែពេលដែលមតកជន បានទទួលមរណភាពហើយនឹងមានការប្រកាសការបាត់ខ្លួនតែប៉ុណ្ណោះ។ ក្នុងករណីដែលមតកជនបានបាត់ខ្លួនមិនមានដំណឹងសោះអស់រយៈពេល៥ឆ្នាំ តុលាការអាចប្រកាសអំពីការបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន ឬ អ្នកដែលមានប្រយោជន៍តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន។ [3] សន្តតិកម្មចាប់ផ្តើមមានអានុភាពនៅពេលដែលសាលក្រមចេញជាស្ថាពរ។ ចំណុចនេះអាចមានលក្ខណៈស្មុគ្រស្មាញ ប្រសិនបើមតកជនបានបង្ហាញខ្លួនមកវិញបន្ទាប់ការប្រកាសបាត់ខ្លួន នោះអានុភាពសន្តតិកម្មត្រូវបានលុបចោលដោយ

[2] សទ្ធានុក្រមផ្នែករដ្ឋប្បវេណី ២០០៧, ទំព័រ ២១។
[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩១។

តាមការទាមទាររបស់សាមីខ្លួន។ ដូចនេះអ្នកទទួលទ្រព្យសម្បត្តិត្រូវបាត់បង់សិទ្ធិដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួនហើយផលប្រយោជន៍ដែលទទួលបានត្រូវបង្វែរមកម្ចាស់ដើមវិញ។ ចុះប្រសិនបើជនដែលត្រឡប់មកវិញមិនបានទាមទារឲ្យលុបសន្តតិកម្មវិញ? ករណីដែលជនដែលបានប្រកាសពីការបាត់ខ្លួនបានវិលត្រលប់មកវិញបន្ទាប់ពីបានបាត់ខ្លួន ទាល់តែជនដែលត្រឡប់មកវិញ មិនទាមទារឲ្យមានការលុបសន្តតិកម្មទេ ដូចនេះសន្តតិកម្មនៅតែមានសុពលភាពដដែល។

### ១.១.២ ទីកន្លែងនៃការចាប់ផ្តើមសន្តតិកម្ម

ការកំណត់ពីទីកន្លែងនៃការចាប់ផ្តើមសន្តតិកម្មគឺវាជាការចាំបាច់ ព្រោះថាលំនៅឋានរបស់មតកជនដើរតួរសំខាន់ក្នុងការកំណត់ទីកន្លែងនៃការចាប់ផ្តើមសន្តតិកម្ម។[4] មានន័យថា តុលាការនៃទីលំនៅរបស់មតកជន ដែលជាអ្នកមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទដែលកើតមានឡើង។ ឧទាហរណ៍ បុគ្គល ក បានទទួលមរណភាព ហើយគាត់មានលំនៅឋាននៅ ក្នុងខេត្តព្រះសីហនុ ដូចនេះពេលមានវិវាទកើតឡើង តុលាការដែលមានសមត្ថកិច្ចគឺ តុលាការខេត្តព្រះសីហនុ។ ប្រសិនបើមតកជនគ្មានលំនៅឋានពិតប្រាកដ តើសន្តតិកម្មត្រូវចាប់ផ្តើមនៅទីកន្លែងណា? ហើយស្ថិតក្រោមដែនសមត្ថកិច្ចរបស់តុលាការណា? ចំណុចទាំងនេះសុទ្ធតែជាបញ្ហាដែលត្រូវពិភាក្សា និងគិតពិចារណា។

ចំណុចនេះគឺជាការពិភាក្សាទាក់ទងនឹងនីតិវិធីរបស់តុលាការ ប្រសិនបើមតកជនមិនមានលំនៅឋានពិតប្រាកដទេ ទីកន្លែងនៃការចាប់ផ្តើមសន្តតិកម្ម គឺទីសំណាក់របស់មតកជន ឬ បើមិនមានទីសំណាក់ទេ ទីកន្លែងនៃចាប់ផ្តើមសន្តតិកម្ម គឺលំនៅឋានចុងក្រោយរបស់មតកជន។ ចំពោះដែនសមត្ថកិច្ចរបស់តុលាការ តុលាការដែលមានសមត្ថកិច្ច គឺតុលាការនៃទីកន្លែងដែលមតកជនទទួលមរណភាព អាចជាលំនៅឋាន ឬ ទីសំណាក់ ឬ លំនៅឋានចុងក្រោយ។[5] លើសពីនេះទៅទៀតប្រសិនបើមតកជនទទួលមរណភាពនៅបរទេសត្រូវគិតលំនៅឋាន ឬ ទីសំណាក់ចុងក្រោយដូចគ្នា។ តុលាការបើកការស្រាវជ្រាវរកឯកសារដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់មតកជន ដើម្បីបន្តនីតិវិធី។

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៦។
[5] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៩។

## ១.២ ប្រភេទនៃសន្តតិកម្ម

សន្តតិកម្មត្រូវបានបែងចែកជាពីរប្រភេទគឺ សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍។[6] មូលហេតុអ្វីបានជាចាំបាច់ត្រូវបែងចែកជាសន្តតិកម្មជាពីរប្រភេទ? ការដែលសន្តតិកម្មកម្ពុជាបានបែងចែកជាពីរប្រភេទ ព្រោះថាបុគ្គលម្នាក់ៗ គឺជាម្ចាស់ដែលមានសិទ្ធិផ្តាច់មុខ ទៅលើទ្រព្យសម្បត្តិដែលខ្លួនមាន។ ដូច្នេះនៅពេលស្លាប់ក៏ដូចគ្នាដែរ គឺមតកជនចង់ទុកទ្រព្យសម្បត្តិរបស់ខ្លួនឲ្យទៅអ្នកណាក៏បានដែរ វាជាសេរីភាពរបស់មតកជន ប្រសិនបើមតកជនបានធ្វើមតកសាសន៍ នៅពេលដែលខ្លួនមានជីវិតរស់នៅ ក្នុងគោលបំណងដើម្បីបង្ហាញឆន្ទៈផ្ទេរទ្រព្យសម្បត្តិទៅឲ្យសន្តតិជនណាម្នាក់ ការបង្ហាញឆន្ទៈនេះជាសន្តតិកម្មតាមមតកសាសន៍។ ចំណែកឯសន្តតិកម្មតាមច្បាប់វិញ ប្រសិនបើមតកជនពុំបានបន្សល់ទុកនូវមតកសាសន៍នោះទេ ដូច្នេះទ្រព្យសម្បត្តិដែលខ្លួនបន្សល់ទុកនោះ ត្រូវបានបែងចែកតាមបញ្ញត្តិនៃច្បាប់ដែលហៅថា សន្តតិកម្មតាមច្បាប់។ បន្ថែមពីនេះទៅទៀត ដោយសារតែ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីសន្តតិកម្មនៅមានកម្រិតនៅឡើយ ប្រជាពលរដ្ឋទូទៅមិនសូវមានទម្លាប់ធ្វើបណ្តាំមតិកកាលនៅរស់ដែលអាចនាំឲ្យមានទំនាស់ក្នុងគ្រួសារដោយសារតែបញ្ហាទ្រព្យសម្បត្តិ ដូច្នេះហើយក្រមរដ្ឋប្បវេណីបាន កំណត់ឲ្យមានសន្តតិកម្មតាមច្បាប់ដើម្បីបញ្ចៀសនូវបញ្ហាទាំងអស់នេះ។

### ១.២.១ សន្តតិកម្មតាមច្បាប់

ចំពោះករណីដែលគ្មានមតកសាសន៍ ការបែងចែកទ្រព្យសម្បត្តិរបស់មតកជនត្រូវធ្វើឡើងតាមរយៈសន្តតិកម្មតាមច្បាប់។ ក្នុងដំណាក់កាលធ្វើសន្តតិកម្មតាមច្បាប់ មានចំណុចពីរសំខាន់គឺ ទី១ ត្រូវដឹងថា មតកជនមានទ្រព្យសម្បត្តិអ្វីខ្លះ? ហើយទី២គឺ តើអ្នកណាខ្លះជាសន្តតិជនដែលត្រូវទទួលបន្តនូវទ្រព្យសម្បត្តិពីមតកជន?

#### ១.២.១.១ សន្តតិជន

ការយល់ដឹងពីសន្តតិជនគឺជាការចាំបាច់នៃការពិភាក្សា ព្រោះថាសន្តតិជនគឺជាអ្នកដែលនឹងត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចពីមតកជន។ ជាធម្មតានៅពេលដែលមតកជនបានទទួល

---

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៥ កថាខណ្ឌទី ២។

មរណភាព តែងតែមានជនត្រូវទទួលបន្តនូវទ្រព្យសម្បត្តិដែលមតកជនបានបន្សល់ទុក ហើយជនដែលទទួលបន្តនេះត្រូវបានច្បាប់កំណត់ថាជា សន្តតិជន។

ការកំណត់ញាតិដែលត្រូវទទួលសន្តតិកម្មពីមតកជនជាការសំខាន់នៃការពិភាក្សា ហើយក៏មានបុគ្គលខ្លះត្រូវបានផ្ដាច់សិទ្ធិពីសន្តតិកម្មនោះផងដែរ។ ដើម្បីទទួលបានសិទ្ធិជាសន្តតិជនលុះត្រាតែបុគ្គលនោះជាជនដែលមានជីវិតរស់នៅនាពេលចាប់ផ្ដើមសន្តតិកម្មទើបអាចទទួលសន្តតិកម្មបាន។ [7] ក្នុងករណីដែលមតកជនមិនបានបន្សល់ទុកមតកសាសន៍ តើច្បាប់ត្រូវដើរតួនាទីយ៉ាងដូចម្ដេចដើម្បីកំណត់ថានរណាខ្លះជាសន្តតិជន?

ការកំណត់ពីសន្តតិជនមានសារៈសំខាន់ណាស់ក្នុងការបែងចែកមតិក។ ហេតុនេះសន្តតិជនត្រូវបានបែងចែកយ៉ាងច្បាស់លាស់ទៅតាមលំដាប់ដោយមានកំណត់ក្នុងច្បាប់។ សន្តតិជនក្នុងក្រមរដ្ឋប្បវេណីកម្ពុជាបានបែងចែកសន្តតិជនជាបីលំដាប់គឺ លំដាប់ទី១ ទៅលំដាប់ទី៣។

លំដាប់ទី១ គឺ កូនរបស់មតកជន។ កូនទោះបីជាកូនបង្កើតក្ដី ឬ កូនសុំក្ដី ឬ ក៏ជាកូនឥតខាន់ស្លាក្ដី ត្រូវមានចំណែកស្មើៗគ្នា។[8] ចំណែកសហព័ទ្ធ និងកូនត្រូវបានចំណែកមតិកស្មើគ្នា[9] ចំណែកឯនៅប្រទេសជប៉ុនវិញ ក៏ដូចជាប្រទេសកម្ពុជាដែរ កូនរបស់មតកជនត្រូវបានក្លាយជាជនលំដាប់ទី១ក្នុងការបែងចែកទ្រព្យសម្បត្តិតាមច្បាប់។[10] ប្រសិនបើមតកជនមានកូន ប៉ុន្តែកូនរបស់មតកជននោះបានស្លាប់តើទ្រព្យសម្បត្តិត្រូវបែងចែកយ៉ាងដូចម្ដេច? ចុះបើកូនរបស់មតកជនមានកូនដែលជាចៅរបស់មតកជន តើចៅនោះអាចទទួលបានទ្រព្យសម្បត្តិជំនួសពី ឪពុកម្ដាយខ្លួនបានដែរឬទេ? ករណីដែលកូនរបស់មតកជនបានស្លាប់ ហើយកូនរបស់មតកជនអត់មានកូន នោះទ្រព្យសម្បត្តិត្រូវធ្លាក់ទៅសន្តតិជនលំដាប់ទី២ ប៉ុន្តែបើកូនរបស់មតកជនមានកូនដែលត្រូវជាចៅរបស់មតកជន ដូចនេះចៅនោះអាចទទួលមតិកបានទៅតាមសមាមាត្រយោងតាមក្រមរដ្ឋប្បវេណីដោយបានកំណត់ថាបើកូនរបស់មតកជនបានទទួលមរណភាពមុនពេលចាប់ផ្ដើមសន្តតិកម្មកូនរបស់បុគ្គលនោះ នឹងក្លាយទៅសន្តតិជនជំនួស។[11] ប្រសិនបើកូនរបស់មតកជននោះមិនបានទទួលមរណភាព ប៉ុន្តែកូន

[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៩ កថាខណ្ឌទី ១។

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៦។

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦២ កថាខណ្ឌទី ២។

[10] មាត្រា ៨៨៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីជប៉ុន ១៨៩៦។

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៧។

នោះជាបុគ្គលដែលបាត់បង់សិទ្ធិសន្តតិកម្ម [12] តើកូនរបស់បុគ្គលបាត់បង់សិទ្ធិសន្តតិកម្មអាចទទួលសន្តតិកម្មនោះបានដែរឬទេ? ចំណុចនេះកូនរបស់បុគ្គលដែលបាត់បង់សិទ្ធិសន្តតិកម្មអាចទទួលទ្រព្យសម្បត្តិពីមតកជនបានយោងតាមក្រមរដ្ឋប្បវេណីដែលបានកំណត់ថា បើកូនរបស់មតកជនបានបាត់បង់សិទ្ធិសន្តតិកម្ម កូនរបស់បុគ្គលនោះត្រូវក្លាយទៅជាសន្តតិជនជំនួស។[13] ប៉ុន្តែមតកជនសុំជនដែលមានកូន តាមរយៈសុំកូនធម្មតា កូនរបស់កូនសុំធម្មតានោះមិនអាចក្លាយជាសន្តតិជនជំនួសបានឡើយ ព្រោះកូនសុំនោះមិនមែនជាបច្ឆាញាតិផ្ទាល់។

លំដាប់ទី២ គឺ បុព្វញាតិផ្ទាល់ បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះត្រូវក្លាយជាសន្តតិជន។ [14] បុព្វញាតិផ្ទាល់ត្រូវបានចាត់ទុកថាជាសន្តតិជនលំដាប់ទី២ ហើយបើបុព្វញាតិផ្ទាល់មានចំនួនច្រើននាក់ បុព្វញាតិនីមួយៗត្រូវទទួលចំណែកមតិកស្មើៗគ្នា។[15] បុព្វញាតិផ្ទាល់របស់មតកជនគឺសំដៅលើជនដែលស្ថិតក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន មានដូចជា ឪពុកម្ដាយ ជីដូនជីតា យាយទួតតាទួត។ សន្តតិជនលំដាប់ទី២នេះគឺត្រូវយកបុព្វញាតិដែលនៅជិតជាងគេ បើគ្មានឪពុកម្ដាយ អ្នកដែលទទួលសន្តតិកម្មគឺ ជីដូនជីតា ហើយបើគ្មានជីដូនជីតា អ្នកដែលទទួលចុងក្រោយគឺ ជីទួតតាទួត ប៉ុន្តែករណីចុងក្រោយនេះកម្រនឹងកើតមានឡើង។ ហេតុអ្វីបានជាបងប្អូនបង្កើតមិនស្ថិតក្នុងសន្តតិជនលំដាប់ទី២ បែរបុព្វញាតិផ្ទាល់ក្លាយជាសន្តតិជនលំដាប់ទី២ទៅវិញ? បានជាបុព្វញាតិផ្ទាល់ត្រូវក្លាយជាសន្តតិជនលំដាប់ទី២ ព្រោះថាបុព្វញាតិផ្ទាល់គឺជា ញាតិខ្សែបណ្ដោយ ហើយបងប្អូនបង្កើតជាញាតិខ្សែទទឹង។ ការរាប់ខ្សែត្រូវចាប់ផ្ដើមរាប់ពី មតកជនទៅក្រោមដែលមានបីថ្នាក់ក្នុងនោះមាន កូន ចៅ និងចៅទួត បន្ទាប់មករាប់ឡើងលើវិញមានបីថ្នាក់ដូចគ្នា រួមមានឪពុកម្ដាយ ជីដូនជីតា និងយាយទួតតាទួត ចុងក្រោយគេរាប់ខ្សែទទឹងដែលមានបងប្អូនបង្កើត។ បន្ថែមពីលើនេះទៅទៀត បុព្វញាតិផ្ទាល់គឺជាអ្នកដែលត្រូវគោរពបូជា ហេតុនេះបានជាទុកអាទិភាពទៅលើបុព្វញាតិផ្ទាល់វិញ។

លំដាប់ទី៣ គឺ បងប្អូនបង្កើត។ បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិ ផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះត្រូវក្លាយជាសន្តតិជន។ [16] ករណីបងប្អូន

---

[12] អភ័ព្វបុគ្គល ឬ ផ្ដាច់ពីមតិក។

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៧។

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៩ កថាខណ្ឌទី ១។

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៩ កថាខណ្ឌទី ២។

[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦០ កថាខណ្ឌទី ១។

បង្កើតណាមានឪពុក ឬ ម្ដាយតែម្ខាងត្រូវបាន ១ភាគ២ នៃបងប្អូនបង្កើត ដែលមានឪពុកម្ដាយរួមគ្នាជាមួយមតកជន។[17] មូលហេតុអ្វីបានជាបងប្អូនបង្កើតម្ដាយ ឬ ឪពុកតែម្ខាងដូចគ្នាត្រូវបានចំណែកតែពាក់កណ្ដាលនៃចំណែកមតិករបស់បងប្អូនដែលមានឪពុក និងម្ដាយទាំងសងខាងដូចគ្នា? ជាធម្មតាប្រសិនបើចែកទ្រព្យសម្បត្តិរវាងបងប្អូនបង្កើតឪពុក និងម្ដាយទាំងសង់ខាងដូចគ្នាស្មើនឹងចំណែករបស់ឪពុក ឬ ម្ដាយតែម្ខាងដូចគ្នា វាហាក់ដូចជាមិនសមរម្យទោះថាជាបងប្អូនគ្នាបង្កើត ប៉ុន្តែជាប់សាច់ឈាមគ្នាតែម្ខាង ហេតុនេះបានច្បាប់កំណត់ឲ្យបងប្អូនបង្កើតឪពុក ឬ ម្ដាយតែម្ខាងដូចគ្នាទទួលបានចំណែកតែពាក់កណ្ដាល ម្យ៉ាងទៀតប្រសិនបើច្បាប់មិនចែកចំណែកឲ្យទៅបងប្អូនបង្កើតឪពុក ឬ ម្ដាយតែម្ខាងក៏ដូចជាមិនសមរម្យព្រោះថាយ៉ាងហោចណាស់បានកើតជាបងប្អូនបង្កើតឪពុក ឬ ម្ដាយដូចគ្នាតែម្ខាងទៅហើយ ហេតុនេះគួរទទួលបានចំណែកពាក់កណ្ដាលដែរទៅ។

បន្ទាប់ពីពិភាក្សាសន្តតិជន៣លំដាប់ អត់ឃើញនិយាយពី សហព័ទ្ធ តើសហព័ទ្ធមិនមានសិទ្ធិទទួលសន្តតិកម្ម ឬ ក៏យ៉ាងណា? វាមិនមែនអញ្ចឹងទេ ក្រៅពីសន្តតិជនទាំងបីលំដាប់ សហព័ទ្ធក៏ជាសន្តតិជនដែរ។ ក្រមរដ្ឋប្បវេណីកម្ពុជាផ្ដល់សិទ្ធិពិសេសដល់សហព័ន្ធ សហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជនអចិន្ត្រៃយ៍។[18] មានន័យថាក្នុងចំណោមលំដាប់ទាំងបី ទោះបីក្នុងលំដាប់ណាមួយក៏ដោយ ក៏មានចំណែករបស់សហព័ទ្ធក្នុងនោះដែរ។ នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជន ហើយមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធត្រូវក្លាយជាសន្តតិជនដែរនោះ សហព័ទ្ធត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ។ ចំពោះការបែងចែកចំណែកមតិក ក្នុងករណីសន្តតិជនជាកូន សហព័ទ្ធត្រូវទទួលបានចំណែកស្មើគ្នាជាមួយនឹងកូននីមួយៗ។ ក្នុងករណីបើគ្មានកូន មតិកត្រូវផ្ទេរទៅសន្តតិជនឪពុកម្ដាយ ទ្រព្យសម្បត្តិត្រូវចែកជាបីចំណែកស្មើគ្នា ដោយមួយចំណែកបានទៅឪពុក មួយចំណែកទៀតបានទៅម្ដាយ និងចំណែកចុងក្រោយបានទៅសហព័ទ្ធ។ ប្រសិនបើមានតែឪពុក ឬ មានតែម្ដាយនៅរស់ សហព័ទ្ធត្រូវបានទ្រព្យពាក់កណ្ដាល ហើយពាក់កណ្ដាលទៀតបានទៅឪពុក ឬ ម្ដាយដែលនៅរស់នោះ។ ប្រសិនបើមតកជនគ្មានកូន និងគ្មានឪពុកម្ដាយនោះសន្តតិកម្មត្រូវធ្លាក់ទៅបងប្អូនបង្កើត ទ្រព្យសម្បត្តិពាក់កណ្ដាលត្រូវបានទៅសហព័ទ្ធហើយនៅសល់ពាក់កណ្ដាលទៀតត្រូវយកទៅចែកជាចំណែកស្មើៗគ្នាឲ្យទៅបងប្អូនបង្កើតនោះ។

---

[17]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២។

[18]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦១ កថាខណ្ឌទី ១។

គួរកត់សម្គាល់ថាច្បាប់កម្ពុជាមិនបានផ្តល់អាទិភាពដល់សហព័ទ្ធរបស់មតកជន។ សម័យមុនប្រពន្ធដើមគឺជាសន្តតិជនលំដាប់ទី៥។ [19] តើជាប្រពៃណីទំនៀមទម្លាប់ ឬ ក៏ដោយសារស្ថានភាពសង្គមនាពេលនោះតម្រូវ? ម្យ៉ាងទៀតពេលនោះច្បាប់ស្តីពីឯកពន្ធភាពមិនទាន់មាននៅឡើយ ដោយសារតែប្តីមានប្រពន្ធច្រើនពេក ឬ ក៏យ៉ាងណា? ចំណែកឯក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ហេតុអ្វីបានជាដាក់សហព័ទ្ធជាសន្តតិជនជានិច្ចវិញ?

កត្តាចំបងមកពីប្រភពច្បាប់ខ្មែរ ប្រទេសកម្ពុជានៅសម័យបុរាណក៏មានប្រព័ន្ធច្បាប់ផងដែរ តែវាមានលក្ខណៈជាច្បាប់មិនសរសេរ ដោយអនុវត្តតែនៅបវេណី។ នៅពេលដែលប្រទេសកម្ពុជាស្ថិតក្រោមរបបអាណានិគមបារាំង កម្ពុជាបានទទួលឥទ្ធិពលច្បាប់ Civil law។ មានន័យថាក្រមរដ្ឋ-ប្បវេណីឆ្នាំ១៩២០ បានចម្លងផ្ទត់គំនិតក្រមរប្បវេណីច្បាប់បារាំង (ក្រមណាប៉ូឡេអុង)។ នាសម័យកាលនោះនៅប្រទេសបារាំង ក៏មិនទាន់ទទួលស្គាល់សិទ្ធិស្ត្រី (សូម្បីតែសិទ្ធិបោះឆ្នោតក៏គ្មានដែរ) មួយវិញទៀត តាមប្រព័ន្ធច្បាប់ Civil law មតិកគឺ ត្រូវផ្ទេរតាមរយៈលោហិត ចំណែកភរិយា មិនមែនជាញាតិលោហិតទេ គឺជាញាតិពន្ធ ហេតុនេះហើយបានជាគេមិនផ្តល់សិទ្ធិដល់ស្ត្រីក្លាយជាសន្តតិជនប្រកួតប្រជែងជាមួយអ្នកដទៃ។ ចំណែកច្បាប់ខ្មែរសម័យបុរាណ ក៏បានបង្ហាញផងដែរ តាមរយៈក្រមមតិក សម័យព្រះបាទនរោត្តម ស្ត្រីគ្មានសិទ្ធិប្រកួតប្រជែងជាមួយសន្តតិជនដទៃទៀត។ កត្តាទាំងនេះហើយ ទើបបានជាក្រមរដ្ឋប្បវេណី១៩២០ មិនអនុញ្ញាតឲ្យស្ត្រីចូលប្រកួតប្រជែងជាមួយសន្តតិជនដទៃទៀត។

បន្ទាប់មកទៀតនៅឆ្នាំ១៩៨១ ទើបមានអនុសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ទើបស្ត្រីមានសិទ្ធិលើវិស័យផ្សេងៗ ដូចជាការងារ នយោបាយ រួមទាំងបញ្ញត្តិពាក់ព័ន្ធនឹងគ្រួសារ។ ដោយសារតែមានការទាមទារសិទ្ធិ បានជាប្រទេសជឿនលឿនធ្វើការកែប្រែប្រព័ន្ធច្បាប់ជាតិរបស់ខ្លួន ដូចជានៅប្រទេស បារាំង ជប៉ុន។ ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីជប៉ុន គឺគេទទួលស្គាល់សិទ្ធិរបស់សហព័ទ្ធនៅរស់ ទោះបីជាសហព័ទ្ធមិនមែនជាញាតិលោហិតក៏ដោយ តែគាត់បានរួមរស់នៅជាមួយគ្នាក្រោមការគ្រប់ដណ្តប់របស់ច្បាប់តែមួយ ដូចជា កាតព្វកិច្ចសាមគ្គីរបស់សហព័ទ្ធ នៅពេលភាគីណាមួយទទួលមរណភាពវាធ្វើឲ្យសហព័ទ្ធដែលនៅរស់ជួបប្រទះនឹងបញ្ហាជាច្រើន ដូចជាការបណ្តេញចេញពីលំនៅដ្ឋានគ្រួសារ ពីសំណាក់សន្តតិជនដទៃទៀត ដោយសារតែពីមុនគាត់មិនមានសិទ្ធិអ្វីទាល់តែសោះ។ ដើម្បីរក្សាសញ្ញាណដើមនៃមតិក ការផ្ទេរទ្រព្យ និងសិទ្ធិ តាមរយៈលោហិត ដូចនេះហើយ ទើបគេអនុញ្ញាតឲ្យសហព័ទ្ធនៅរស់ចូលរួមប្រកួតប្រជែងជាមួយសន្តតិជនដទៃទៀត។ ក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧ ក៏ដូចគ្នាផងដែរ។

---

[19] ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩២០, មាត្រា ៥៩៧។

## រូបភាពទី១ លំដាប់នៃសន្តតិជន

| រូបភាព | សន្តតិជន | លំដាប់ សន្តតិជន | |
|---|---|---|---|
|  | យាយទួត តាទួត (ករណីគ្មាន ជីដូន ជីតា) | ២ | បុព្វញាតិ |
|  | ជីដូន ជីតា (ករណីឪពុកម្តាយស្លាប់) | | |
|  | ឪពុក ម្តាយ (ករណីគ្មានលំដាប់ទី១) | | |
|  សហព័ទ្ធ (សន្តតិជនជានិច្ច) | បងប្អូនបង្កើត (ករណីគ្មានលំដាប់ទី២) | ៣ | បងប្អូនបង្កើត |
|  | កូន | ១ | បច្ឆាញាតិ |
|  | ចៅ (ករណីកូនស្លាប់) | | |
|  | ចៅទួត (ករណីចៅស្លាប់) | | |

តើជនបរទេសអាចក្លាយជាសន្តតិជនបានដែរឬទេ? នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មិនបានកំណត់ច្បាស់ថា បុគ្គលដែលជាសន្តតិជនត្រូវមានសញ្ជាតិអ្វីនោះទេ ប៉ុន្តែជាទូទៅការអនុវត្តសន្តតិកម្មកម្ពុជាគឺ ផ្តោតទៅលើប្រជាពលរដ្ឋដែលមានសញ្ជាតិខ្មែរ។ ទោះជាយ៉ាងណាក៏ដោយមានមាត្រាមួយនៃក្រមរដ្ឋប្បវេណីបានកំណត់ថា ជនបរទេសក៏អាចក្លាយជាសន្តតិជនបានដែរ។ ជនបរទេសដែលជាសន្តតិជនភាគច្រើនទទួលបានទ្រព្យសម្បត្តិតាមរយៈមតកសាសន៍ ឬ ក៏សហព័ទ្ធរបស់មតកជនជាជនបរទេស។ សន្តតិជនដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ ពុំមានសញ្ជាតិខ្មែរទេ ជននោះពុំអាចទទួលដីធ្លី តាមសន្តតិកម្ម ឬ តាមអច្ច័យទានបានឡើយ។[20] ហេតុនេះមានចំនោទបញ្ហាមួយលើកឡើងថា បើសន្តតិជនជាជនបរទេស ហើយត្រូវទទួលដីធ្លីតាមរយៈមតកសាសន៍ តើច្បាប់បានកំណត់នីតិវិធីយ៉ាងដូចម្តេច? វាជាបញ្ហាសំខាន់នៃការពិភាក្សា ជាការពិតណាស់បើយោងតាមច្បាប់ភូមិបាលកម្ពុជា ជនដែលគ្មានសញ្ជាតិខ្មែរ ពុំអាចមានសិទ្ធិកម្មសិទ្ធិលើដីធ្លីទេ។ ប៉ុន្តែបើទ្រព្យសម្បត្តិនៃសន្តតិកម្មជាអគារសហកម្មសិទ្ធិ ច្បាប់ស្តីពី ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស នោះសន្តតិជនជាជនបរទេសអាចមានសិទ្ធិកម្មសិទ្ធិចាប់ពីជាន់ទី១ ឡើងទៅ។ បើសន្តតិកម្មជាដីធ្លីវិញ ហេតុនេះសន្តតិជនបរទេសមិនមានសិទ្ធិចាត់ចែងលើដីធ្លីនេះទេ ដូច្នេះត្រូវចាត់ទុកថាដីធ្លីដែលជាមតិកនេះជានីតិបុគ្គលមូលនិធិ ហើយនីតិបុគ្គលនោះមានកម្មសិទ្ធិទៅលើដីធ្លី ហើយសន្តតិជនមានសិទ្ធិគ្រប់គ្រងចាត់ចែងបានដីនោះ។ ប្រសិនបើដីធ្លីគ្មានម្ចាស់ នោះដីធ្លីនឹងក្លាយជាទ្រព្យសម្បត្តិរដ្ឋ។ បន្ថែមពីនេះទៅទៀត ការដាក់ដីធ្លីក្រោមកម្មសិទ្ធិជានីតិបុគ្គល ត្រូវកម្រិតអំឡុងពេល បី ខែ ជាអំឡុងពេលចាត់ចែង ប្រសិនបើ មិនមានការចាត់ចែងដីធ្លីនោះទេ សន្តតិជនដែលមានលំដាប់បន្ទាប់ជាសន្តតិជនវិញ។[21]

ការទទួលបន្តនូវទ្រព្យសម្បត្តិរបស់មតកជនត្រូវមានសន្តតិជនទទួលបន្ត ហេតុនេះមានចំនោទបញ្ហាលើកឡើងថា ប្រសិនបើអត់មានសន្តតិជនទាំងបីលំដាប់ ហើយគ្មានសន្តតិជនជំនួសទៀត តើទ្រព្យសម្បត្តិត្រូវក្លាយទៅជាទ្រព្យសម្បត្តិរដ្ឋ ឬក៏យ៉ាងណា? តាមការពិតមិនមែនចឹងទេ មុននឹងទ្រព្យសម្បត្តិរបស់មតកជនត្រូវក្លាយទៅជាទ្រព្យសម្បត្តិរដ្ឋ នៅមានករណីពិសេសមួយទៀត គឺ ការបែងចែកមតិកឲ្យទៅអ្នកដែលមាននិស្ស័យពិសេស។ ករណីនេះបើតុលាការយល់ឃើញថាសមរម្យតុលាការអាចចែកមួយផ្នែកនៃមតិកដែលនៅសល់ក្រោយពីការជម្រះ ទៅឲ្យជនដែលមានជីវភាព

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៥។

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៥ កថាខណ្ឌទី៥។

ជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និងជនដែលមាននិស្ស័យពិសេសផ្សេងទៀត តាមពាក្យសុំរបស់ជននោះ។[22] ជាក់ស្តែងណាស់ក្នុងសង្គមណាក៏ដោយក៏នៅមានបុគ្គលខ្លះដែលបានរស់នៅម្នាក់ឯងសឹងតែមួយជីវិត ដល់ពេលចាស់ជរា ស្លាប់ទៅគ្មានសន្តតិជនទទួលទ្រព្យសម្បត្តិបន្ត ឬ បុគ្គលខ្លះទៀតមិនបានរៀបអាពាហ៍ពិពាហ៍ ហើយរស់នៅជាមួយបងប្អូនជីដូនមួយ ឬ ពូមីង។ ជាការពិតណាស់ បងប្អូនជីដូនមួយ និងពូមីងមិនមានសិទ្ធិក្លាយជាសន្តតិជនទេ ប៉ុន្តែដោយសារតែរស់នៅជាមួយគ្នាមានភាពសុខដុមជាមួយគ្នា ហេតុនេះអ្នកទាំងនោះអាចដាក់ពាក្យសុំទៅតុលាការ ដើម្បីអាចទទួលសន្តតិកម្មបាន។ ម្យ៉ាងវិញទៀតរយៈពេលនៃការដាក់ពាក្យសុំនោះមានអំឡុងពេល ៣ខែ ក្រោយពីអំឡុងពេលដែលបានជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន។ បន្ទាប់ពីចែកមួយផ្នែកដែលតម្លៃសរុបមិនលើសពីចំនួនពាក់កណ្តាលនៃមត៌កដែលនៅសេសសល់ទៅអ្នកមាននិស្ស័យពិសេសរួច ទ្រព្យសម្បត្តិដែលនៅសេសសល់ប៉ុន្មានត្រូវក្លាយជាសម្បត្តិរដ្ឋ ឬ ក៏មត៌កគ្មានសន្តតិជន ហើយមិនមានអ្នកដែលមាននិស្ស័យពិសេសត្រូវក្លាយជាសម្បត្តិរដ្ឋ។[23]

យ៉ាងណាមិញក៏នៅតែមានជនមួយចំនួនដែលមិនអាចមានសិទ្ធិទទួលបាននូវសន្តតិកម្មឡើយ ប្រសិនបើជនទាំងនោះបានប្រព្រឹត្តនូវកំហុសធ្ងន់ធ្ងរ។ ចំណុចនេះមានសារៈសំខាន់ នៃការពិភាក្សាថាជនណាខ្លះមានសិទ្ធិជាទទួលសន្តតិកម្ម និងជនណាខ្លះទៀតដែលមិនមានសិទ្ធិទទួលសន្តតិជន? ជនដែលមិនអាចមានសិទ្ធិទទួលបានសន្តតិកម្ម អាចហៅម្យ៉ាងទៀតបានថា ជាអភ័ព្វបុគ្គល។

ក្រមរដ្ឋប្បវេណីកម្ពុជាកំណត់ដែលជា អភ័ព្វបុគ្គលដូចខាងក្រោម ៖

- បុគ្គលដែលទទួលទោសដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី។
- បុគ្គលដែលដឹងអំពីការសម្លាប់របស់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង។
- បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោក ឬ [គំរាម] កំហែង។
- បុគ្គលដែលបានឲ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោក ឬ [គំរាម]កំហែង។

---

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៩។
[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៣០០។

_បុគ្គលដែលបានក្លែងបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្ម របស់មតកជន។[24]

ចំណែកការផ្តាច់មត៌កពីសន្តតិជនវិញ មតកជនអាចដាក់ពាក្យសុំទៅតុលាការ ឲ្យផ្តាច់មត៌កពីជនដែលសន្មតជាសន្តតិជនមិនឲ្យទទួលសន្តតិកម្មបាន ប្រសិនបើជននោះបានប្រព្រឹត្តសកម្មភាពដូចជា

- បើបានធ្វើបាបចំពោះមតកជន
- បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ
- បើអាចមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ
- បើត្រូវបានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត
- បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឲ្យកត់[សម្គាល់]ជាអាទិ៍។[25]

## ១.២.១.២ ការសម្រួលចំណែកមត៌ក

គួរកត់សម្គាល់ផងដែរការសម្រួលចំណែកមត៌កជាការចាំបាច់នៃការពិភាក្សា ព្រោះថាជាគោលការណ៍ សន្តតិជនត្រូវទទួលបានចំណែកស្មើៗគ្នា ប៉ុន្តែប្រសិនបើមានសន្តតិជនណាក្នុងចំណោមសន្តតិជនទាំងអស់បានទទួលផលប្រយោជន៍មុនពេលចាប់ផ្តើមសន្តតិកម្ម វាធ្វើឲ្យខូចប្រយោជន៍ដល់សន្តតិជនដែលពុំទាន់បានទទួលផលប្រយោជន៍ផ្សេងៗ ដើម្បីការពារប្រយោជន៍ដល់សន្តតិជនដែលពុំទាន់បានទទួលផលប្រយោជន៍នោះ នាំឲ្យច្បាប់មានប្បញ្ញត្តិស្តីពី ការសម្រួលចំណែកមត៌កហេតុនេះដើម្បីឲ្យមានសភាពត្រឹមត្រូវរវាងសហសន្តតិជន។ ផលប្រយោជន៍ពិសេស គឺជាផលប្រយោជន៍ដែលបុគ្គលណាបានទទួលជាប្រទានកម្ម នៅពេលរៀបអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ពីមតកជនពេលនៅរស់។ លើសពីនេះ អច្ច័យទានដែលសន្តតិជនទទួលបានក៏ចាត់ទុកជាប្រយោជន៍ពិសេសផងដែរ ប៉ុន្តែអច្ច័យទាន ពុំត្រូវរាប់បញ្ចូលដើម្បីគណនាទេ ព្រោះថាអច្ច័យទាន ពុំទាន់ត្រូវបានបែងចែកឲ្យទៅសន្តតិជនឡើយនៅពេលចាប់ផ្តើមសន្តតិកម្ម ម្យ៉ាងវិញទៀត ប្រទានកម្មដែលជាផលប្រយោជន៍របស់តតិយជន អាចជាកម្មវត្ថុនៃការគណនាភាគបម្រុងបាន កាលដែលប្រទានកម្មនោះធ្វើឡើងនៅក្នុងអំឡុងពេល ១ឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្ម ឬ ក៏ប្រទានកម្មដែលធ្វើឡើងដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្តាលឲ្យខូចខាតដល់អ្នកមាន

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥០។

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥១។

សិទ្ធិលើភាគបម្រុង ហើយការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរត្រូវចាត់ទុកថាជាប្រទានកម្មផងដែរ។[26] តើចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស ត្រូវសម្រួលយ៉ាងដូចម្ដេច?

វិធីសម្រួលចំណែកមតិក វាជាការចាំបាច់ត្រូវដឹងថាតើផលប្រយោជន៍ពិសេសជាអ្វី? ព្រោះថាក្នុងគោលបំណងនៃការសម្រួលនូវចំណែកមតិកគឺសម្រាប់អ្នកបានទទួលផលប្រយោជន៍ពិសេសក្នុងចំណោមសន្តតិជនទាំងអស់។ ឧបមាថាសន្តតិជនណាម្នាក់ឬច្រើននាក់ ពេលដែលសន្តតិជនណាម្នាក់បានរៀបអាពាហ៍ពិពាហ៍ មតកជនពេលនៅរស់បានចងដៃសន្តតិជននោះជាប្រាក់ ឬ វត្ថុមានតម្លៃផ្សេងទៀត ទ្រព្យនេះជាកម្មវត្ថុនៃការសម្រួលចំណែកមតិក ឬ អាចហៅបានថាជាផលប្រយោជន៍ពិសេស។ តម្លៃសរុបនៃមតិក គឺត្រូវយកទ្រព្យរបស់មតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្មបូកបញ្ចូលតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកជាមតិក បន្ថែមពីចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីការដកតម្លៃនៃប្រទានកម្ម ឬ អច្ច័យទានចេញពីចំណែកមតិក គឺជាចំណែកមតិករបស់បុគ្គលនោះ។[27] មតិកសរុបស្មើនឹង ការបូករវាងមតិក និងប្រទានកម្ម ឬ អច្ច័យទាន។

### ១.២.២ សន្តតិកម្មតាមមតកសាសន៍

ការកំណត់ទម្រង់លិខិតមតកសាសន៍ និងទ្រព្យសម្បត្តិដែលត្រូវបែងចែកសម្រាប់សន្តតិកម្មតាមមតកសាសន៍ជាការចាំបាច់នៃការពិភាក្សា។ សន្តតិកម្មតាមមតកសាសន៍ គឺជាការបង្ហាញឆន្ទៈឯកតោភាគី ដោយពុំមានភាគីម្ខាងទៀត ដែលធ្វើដោយម្ចាស់បណ្ដាំពាក់ព័ន្ធនឹងចំណុចពិសេសស្ដីពីទំនាក់ទំនងទ្រព្យសម្បត្តិរបស់ជននោះ ឬ ស្ដីពីទំនាក់ទំនងឋានៈបុគ្គល ក្នុងគោលបំណងបង្កើតអានុភាព នៅពេលដែលខ្លួនទទួលមរណភាពហើយដែលបានធ្វើទៅតាមវិធីកំណត់ជាក់លាក់។ ប្រសិនបើមានមតកសាសន៍ តើម្ចាស់ទ្រព្យមានសិទ្ធិបែងចែកកេរ្ដិ៍មតិករបស់ខ្លួនយ៉ាងម៉េចក៏បាន ឬក៏យ៉ាងណា? ការធ្វើសន្តតិកម្មតាមមតកសាសន៍ ម្ចាស់ទ្រព្យអាចផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនទៅអ្នកណាក៏បានដែរ ក៏ប៉ុន្តែការផ្ទេរនោះត្រូវគោរពគោលការណ៍មួយដ៏សំខាន់ គឺត្រូវគោរពតាមភាគបម្រុង។ ចំពោះភាគបម្រុងនឹងមានពិភាក្សានៅចំណុចបន្ទាប់។ មតកសាសន៍ ដែលពុំបានធ្វើឡើងតាមវិធីដែលបានកំណត់ក្នុងច្បាប់ទេ ពុំមានអានុភាពឡើយ។[28] ក្នុងករណីដែលមតកជនចង់ផ្ដាច់មតិកពីសន្តតិជនមតកជនត្រូវមានការពន្យល់ឲ្យបានច្បាស់លាស់អំពីមូលហេតុដែលចង់លុបមតកសាសន៍ ។

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៣២។
[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៣។
[28] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧០។

### ១.២.២.១ សមត្ថភាពក្នុងការធ្វើមតកសាសន៍

ការធ្វើមតកសាសន៍ បុគ្គលត្រូវមានសមត្ថភាពដែលកំណត់ដោយច្បាប់ តើច្បាប់បានកំណត់ថាបុគ្គលណាខ្លះដែលមានសមត្ថភាពក្នុងការធ្វើមតកសាសន៍ទើបមានសុពលភាព? ក្នុងការកំណត់អំពីអ្នកដែលមានសមត្ថភាពធ្វើមតកសាសន៍ច្បាប់បានកំណត់ថា បុគ្គលដែលជានីតិជន និងអនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបាសុទ្ធតែមានសិទ្ធិអាចធ្វើមតកសាសន៍បាន។[29] លើសពីនេះទៅទៀត ម្ចាស់បណ្តាំ ត្រូវស្ថិតក្នុងស្ថានភាពដែលមានសមត្ថភាពអាចវិនិច្ឆ័យបានត្រឹមត្រូវ មិនមែនស្ថិតក្នុងស្ថានភាពវិបល្លាសស្មារតី នៅក្នុងអំឡុងពេលធ្វើមតកសាសន៍របស់ខ្លួន។ ដូច្នេះ ម្ចាស់បណ្តាំត្រូវមានសមត្ថភាពគ្រប់គ្រាន់ផ្នែកស្មារតី និងស្របទៅតាមច្បាប់បានកំណត់នៅពេលធ្វើមតកសាសន៍។[30]

### ១.២.២.២ ទម្រង់នៃមតកសាសន៍ និងមតកសាសន៍សម្រាប់ជនស្ថិតក្នុងករណីពិសេស

ការយល់ដឹងពីទម្រង់នៃមតកសាសន៍ជាការចាំបាច់សម្រាប់អ្នកមានបំណង់ចង់ធ្វើមតក-សាសន៍ពេលដែលខ្លួននៅរស់។ ទម្រង់នៃមតកសាសន៍ដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការបែងចែកមានបីប្រភេទគឺ មតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតឯកជន និងមតកសាសន៍ដោយលិខិតសម្ងាត់។

មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី។ ដែលលិខិតនេះត្រូវមាន វត្តមានរបស់សាក្សីយ៉ាងតិចពីរនាក់ ហើយសារការីត្រូវសរសេរអំពីខ្លឹមសារនៃមតកសាសន៍នោះជាលាយលក្ខណ៍អក្សរ ម្យ៉ាងទៀតត្រូវអានឲ្យម្ចាស់បណ្តាំស្តាប់។ បន្ទាប់មកទៀត ម្ចាស់បណ្តាំ សាក្សី និងសារការី ត្រូវចុះហត្ថលេខា ទៅលើលិខិតនោះ។ សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា។[31] ការធ្វើមតកសាសន៍ជាលិខិតយថាភូតនេះមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ ព្រោះដោយសារតែមានសារការីជាអ្នកធ្វើមតកសាសន៍។ មិនតែប៉ុណ្ណោះ ប្រសិនបើ មតកជន ជាអនក្ខរជន មតកជននៅតែអាចមានលទ្ធភាពធ្វើបណ្តាំមត៌កបានដោយមានការជួយពីសារការី ជាអ្នកសរសេរជំនួសដោយមិនមានការក្លែងបន្លំ ហើយការធ្វើមតកសាសន៍ជាលិខិតយថាភូតនេះមិន ចាំបាច់មាននីតិវិធីបញ្ជាក់ទេនៅពេលដែលចាប់ផ្តើមអនុវត្ត។ ទន្ទឹមនឹងនេះ

[29]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៨ កថាខណ្ឌទី ១។
[30]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៩ កថាខណ្ឌទី ១។
[31]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៣។

ក៏នៅមានផលវិបាក មួយចំនួនបានចោទឡើងដោយសារតែការធ្វើបណ្តាំមតិកដោយលិខិតសម្ងាត់នេះចាំបាច់ត្រូវតែមានការចូលរួមពីសារការី។ ម្យ៉ាងវិញទៀតការចូលរួមរបស់សារការី ធ្វើឲ្យមតកជនត្រូវចំនាយថវិកាដើម្បីជួល។ ដើម្បីការពារកុំឲ្យបាត់ ឬ កុំឲ្យមានការក្លែងបន្លំបាន នៅប្រទេសជប៉ុន សារការីជាអ្នករក្សាទុកលិខិតយថាភូតនេះ។

យោងតាមការសិក្សាស្រាវជ្រាវច្បាប់របស់ប្រទេសជប៉ុនទម្រង់នៃលិខិតយថាភូតក៏មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាដែរ។ លិខិតយថាភូតរបស់ប្រទេសជប៉ុនត្រូវធ្វើឡើងដោយៈ

- ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិចពីរនាក់
- អ្នកធ្វើបណ្តាំមតិក ត្រូវធ្វើការណែនាំដោយផ្ទាល់មាត់នៃមតកសាសន៍នៅចំពោះមុខសារការី
- សារការីត្រូវសរសេរនូវអ្វីដែលអ្នកធ្វើបណ្តាំមតិកបានអានដោយលឺឬក៏អនុញ្ញាតឲ្យអ្នកធ្វើបណ្តាំមតិក និងសាក្សីធ្វើការពិនិត្យមើល
- អ្នកធ្វើបណ្តាំមតិក និងសាក្សី ត្រូវចុះហត្ថលេខា និងភ្ជាប់ជាមួយត្រារបស់ពួកគេ លិខិតបញ្ជាក់បន្ទាប់ពី បានយល់ព្រម ប៉ុន្តែក្នុងករណីដែលអ្នកធ្វើបណ្តាំមតិកមិនអាចចុះហត្ថលេខា សារការីត្រូវចុះហត្ថលេខាជំនួស ជាមួយនិងហេតុចុះបញ្ជីជំនួស និងសារការី ត្រូវចុះបញ្ជីបន្ថែមដើម្បីឲ្យលិខិតបញ្ជាក់មានសុពលភាព លិខិតបញ្ជាក់ត្រូវធ្វើទៅតាមទម្រង់ត្រឹមត្រូវដែលបានទាមទារ ការចុះហត្ថលេខា និងភ្ជាប់ជាមួយត្រារបស់មតកជន។[32]

ក្រៅពីនេះមតកសាសន៍ដោយលិខិតឯកជនក៏ជាទម្រង់មួយនៃមតកសាសន៍ផងដែរលិខិតឯកជនត្រូវធ្វើឡើងដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់ និងចុះថ្ងៃខែឆ្នាំដោយខ្លួនឯងហើយត្រូវចុះហត្ថលេខាលើលិខិតនោះ។ មតកសាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទ៍ នឹងត្រូវចាត់ទុកជាមោឃៈ។ ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនូវកន្លែងហើយសរសេរបន្ថែមនូវហេតុនៃការប្រែនោះ

ជាពិសេសបើមិនបានចុះហត្ថលេខាទេ។[33] ការធ្វើបណ្តាំមតិកជាលិខិតឯកជននេះ មតកជនអាចធ្វើដោយខ្លួនឯងបានដោយមិនបាច់មានសារការី មិនចាំបាច់ចំណាយថវិកាជាពិសេសអាចរក្សាការសម្ងាត់បាន។ ក៏ប៉ុន្តែការធ្វើលិខិតសម្ងាត់នេះអាចនឹងមិនមានសុពលភាពដោយសារតែមានការ

[32] ក្រមរដ្ឋប្បវេណីជប៉ុន, ឆ្នាំ ១៨៩៦, មាត្រា ៩៦៩។

[33]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៥។

ផ្ទុយនឹងទម្រង់។ ជាពិសេសប្រសិនបើមតកជនជាអនក្ខរជននោះ មតកជនមិនអាចមានលទ្ធភាពធ្វើបណ្ដាំមតិកបាន ឡើយ។ លិខិតឯកជននេះចាំបាច់ត្រូវពិនិត្យសារឡើងវិញ ជៀសវាងការក្លែងបន្លំ។

ក្រៅពីមតកសាសន៍ជាលិខិតយថាភូត និងមតកសាសន៍ជាលិខិតឯកជនក៏នៅមានទម្រង់មួយបែបទៀតគឺ មតកសាសន៍ដោយលិខិសម្ងាត់។ មតកសាសន៍ដោយលិខិតសម្ងាត់គឺជាលិខិតសម្ងាត់តម្រូវឲ្យមានហត្ថលេខារបស់ម្ចាស់បណ្ដាំ និងស្ថិតក្នុងស្រោមសំបុត្របិទជិត ដោយមានសញ្ញាសម្គាល់មិនបានបើក។ ម្ចាស់បណ្ដាំត្រូវដាក់លិខិតដែលបានបិទជិតនៅចំពោះមុខសារការីម្នាក់ និងសាក្សីពីរនាក់ និងធ្វើសេចក្ដីថ្លែងការណ៍ថាលិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួនហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ។ សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតសម្ងាត់ និងសរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំនៅលើលិខិតដែលបិទជិតហើយត្រូវចុះហត្ថលេខាលើលិខិតជាមួយគ្នានឹងសាក្សី និងម្ចាស់បណ្ដាំ។[34] លិខិតសម្ងាត់អាចប្រើម៉ាស៊ីនធ្វើឯកសារបាន ឬ ក៏អាចឲ្យអ្នកដទៃសរសេរជំនួសបាន។ ម្យ៉ាងទៀត ទោះបីមិនស្របនឹងលក្ខខណ្ឌនៃមតកសាសន៍ដោយលិខិតសម្ងាត់ក៏ដោយ ក៏មានសុពលភាពជាមតកសាសន៍ដោយលិខិតឯកជនដែរ។ [35] ការធ្វើបណ្ដាំមតិកដោយលិខិតសម្ងាត់នេះអាចជួយរក្សា ការសម្ងាត់ និងការពារការក្លែងបន្លំ។ ប៉ុន្តែការធ្វើដោយលិខិតសម្ងាត់ ក៏ដូចជាការធ្វើដោយលិខិតយថាភូតដែរ ដោយចាំបាច់ត្រូវវត្តមានរបស់សារការី។ ម្យ៉ាងទៀតលិខិតសម្ងាត់ពេលអនុវត្តត្រូវធ្វើនីតិវិធីពិនិត្យបញ្ជាក់ផងដែរ។

[34]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៥។
[35]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧១។

តារាងខាងក្រោមបង្ហាញពីភាពខុសគ្នា រវាងមតកសាសន៍ដោយ លិខិតយថាភូត លិខិតឯកជន និងលិខិតសម្ងាត់។

តារាងទី ១ ប្រភេទនៃលិខិតមតកសាសន៍

| ប្រភេទ | បរិយាយ | | |
|---|---|---|---|
| | លក្ខណៈពិសេសនៃលិខិត | សាក្សី | ហត្ថលេខា |
| មតកសាសន៍ដោយលិខិតយថាភូត | សារការីជាអ្នកសរសេរ | សាក្សីយ៉ាងតិច ពីរនាក់ | ហត្ថលេខាម្ចាស់បណ្ដាំ និង ឬ សារការី និងសាក្សី |
| មតកសាសន៍ដោយលិខិតឯកជន | ម្ចាស់បណ្ដាំ ជាអ្នកសរ-សេរដោយដៃផ្ទាល់ | មិនចាំបាច់មានសាក្សី | ត្រូវមានហត្ថលេខាម្ចាស់បណ្ដាំ |
| មតកសាសន៍ដោយលិខិតសម្ងាត់ | ម្ចាស់បណ្ដាំ ធ្វើសេចក្ដី-ថ្លែងការណ៍ លើលិខិតសម្ងាត់របស់ខ្លួន | សាក្សីពីរនាក់ និងសារការី | ត្រូវមានហត្ថលេខាម្ចាស់បណ្ដាំ សារការី និងសាក្សីលើសេចក្ដីថ្លែងការណ៍ |

មតកសាសន៍សម្រាប់ជនដែលស្ថិតនៅក្នុងស្ថានភាពពិសេស ដែលស្ថានភាពនេះមានមតក-សាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំង មតកសាសន៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ មតកសាសន៍របស់ជនដែលមិនអាចនិយាយបាន។

ដើម្បីធ្វើមតកសាសន៍របស់ជន នៅក្រោមអាណាព្យាបាលទូទៅ លុះត្រាតែជននោះបានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ពីរនាក់។ វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅ

ពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ។[36]

មតកសាសន៍របស់ជន ដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឲ្យមានវត្តមានរបស់សាក្សីយ៉ាងតិច បីនាក់ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះដោយផ្ទាល់មាត់ចំពោះជនម្នាក់ក្នុងចំណោមសាក្សីនោះ។ នៅក្នុងករណីនេះជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយអានឲ្យសាក្សីស្តាប់ ឬ ឲ្យមើលហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះត្រូវចុះហត្ថលេខាលើលិខិតនោះ។ ដើម្បីឲ្យលិខិតនេះមានអានុភាព បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវដាក់ពាក្យសុំទៅតុលាការ ក្នុងអំឡុងពេល ១ខែ ដោយគិតពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ត្រូវមានការបញ្ជាក់ពីតុលាការ។ ហើយក្នុងករណីដែលតុលាការទទួលស្គាល់ថាខ្លឹមសារនោះគឺជាឆន្ទៈពិតរបស់ម្ចាស់បណ្តាំ ពេលនោះមតកសាសន៍នឹងមានសុពលភាព។[37]

មតកសាសន៍របស់ជន ដែលត្រូវជាប់ឃុំឃាំង ចំពោះជន ដែលត្រូវជាប់ឃុំឃាំង ឬ ជនដែលនៅលើនាវា ឬ នៅក្នុងយន្តហោះ បើសិនជាអាចធ្វើមតកសាសន៍បាន (លិខិតឯកជន) ជននោះអាចធ្វើមតកសាសន៍ដោយធម្មតាបាន។ ក៏ប៉ុន្តែប្រសិនបើជននោះ ជាអនក្ខរជន ឬ មានរបួសដៃ ដូច្នេះគាត់មិនអាចធ្វើ មតកសាសន៍ដោយលិខិតឯកជន ព្រោះថាលិខិតឯកជនចាំចាច់គឺគាត់ជាអ្នកសរសេរ ហេតុនេះត្រូវផ្លាស់ប្តូរ ពីលិខិតឯកជន ទៅជាលិខិតយថាភូត ចំពោះនីតិវិធីនេះ គឺនគរបាល ឬ នាវិក នាយក ជាដើម នឹងមានតួនាទីជាសារការី។ បន្ថែមពីនេះទៅទៀតលិខិតនេះគឺគ្រាន់តែធ្វើឡើងក្នុងករណីបណ្តោះអាសន្នទេ ហេតុនេះមតកសាសន៍នឹងបាត់បង់នូវអានុភាព ៦ខែ ក្រោយពេលចេញពីកន្លែងឃុំឃាំង ឬ ក្រោយពេលចុះពីនាវា។[38]

[36]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៦។
[37]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៧។
[38]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៨។

មតកសាសន៍របស់ជនដែលមិនអាចនិយាយបាន ករណីជនដែលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់ដោយច្បាប់ ម្ចាស់បណ្ដាំនោះអាចជំនួសការប្រាប់បានដោយធ្វើសេចក្ដីថ្លែងការណ៍ អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្ដីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី។ ប៉ុន្តែប្រសិនបើ ម្ចាស់បណ្ដាំ និងសាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្ដាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់ អាចជំនួសការអានឲ្យស្ដាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្ដាំ ឬ សាក្សីនោះ។[39]

## ១.៣. ភាគបម្រុង

ភាគបម្រុងគឺជារបបធានាមួយភាគនៃចំណែកមតិកធានាដោយច្បាប់ ចំពោះសន្តតិជនកំណត់ដោយច្បាប់។ ជាការពិតណាស់មតកជនមានសេរីភាពក្នុងការធ្វើមតកសាសន៍ ក៏ប៉ុន្តែរបបនេះបានទទួលស្គាល់ឲ្យសន្តតិជនដែលកំណត់ដោយមួយចំនួន ហើយធ្វើការបដិសេធនូវសេរីភាពនេះមួយភាគ។ របបភាគបម្រុងនេះមានតួនាទីសម្រួលសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍។ មូលហេតុអ្វីបានជាត្រូវបង្កើតភាគបម្រុង? ការបង្កើតឲ្យមានភាគបម្រុងនេះ គឺដើម្បីការពារប្រយោជន៍ឲ្យសន្តតិជន ព្រោះថាប្រសិនបើមតកជនបានធ្វើមតកសាសន៍មុនពេលទទួលមរណភាព ករណីដែលគាត់ធ្វើមតកសាសន៍ផ្ទេរទ្រព្យរបស់គាត់ទាំងអស់ទៅឲ្យ តតិយជនដែលមិនមែនជាសន្តតិជន នេះជាហេតុធ្វើឲ្យខូចប្រយោជន៍របស់សន្តតិជន។ ការពិតហើយវាជាឆន្ទៈរបស់មតកជន ប៉ុន្តែក្រមរដ្ឋប្បវេណីកម្ពុជា បង្កើតភាគបម្រុងនេះឡើង ដើម្បីការពារប្រយោជន៍អ្នកដែលជាសន្តតិជនប៉ុណ្ណោះ ដោយមិនចង់ឲ្យទ្រព្យសម្បត្តិធ្លាក់ទៅជនដែលមិនមែនជាសាច់ញាតិរបស់មតកជន។ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុងមាន អច្ច័យទាន ការកំណត់ចំណែកមតិកតាមមតកសាសន៍ ផលប្រយោជន៍ពិសេស និងប្រទានកម្មមួយចំនួននាពេលនៅរស់ ភាគបម្រុងបានការពារនូវភាគបម្រុង តាមរយៈការបដិសេធនូវអានុភាពនៃសកម្មភាពទាំងនេះ។ ចំណុចបន្ទាប់នឹងធ្វើការពន្យល់ពី តើអ្នកណាមានសិទ្ធិលើភាគបម្រុង ហើយត្រូវកាត់បន្ថយភាគបម្រុងយ៉ាងដូចម្ដេច?

[39]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៩។

### ១.៣.១ អ្នកមានសិទ្ធិលើភាគបម្រុង

ការកំណត់អ្នកណាខ្លះជាអ្នកមានសិទ្ធិលើភាគបម្រុងជាការចាំបាច់នៃការពិភាក្សា។ អ្នកមានសិទ្ធិលើភាគបម្រុង គឺមានដូចជា បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្ដាយ ឬ ជីដូនជីតា នឹងសហព័ទ្ធរបស់មតកជន រីឯបងប្អូនពុំមានសិទ្ធិលើភាគបម្រុងទេ។ ជាគោលការណ៍ចំណែកនៃភាគបម្រុងគឺ ១ភាគ ២ នៃទ្រព្យសម្បត្តិរបស់មតកជន ប៉ុន្តែប្រសិនបើសន្តតិជនជា ឪពុកម្ដាយ ឬ ជីដូនជីតា គឺ ១ភាគ៣ នៃទ្រព្យសម្បត្តិរបស់មតកជន។ បន្ទាប់មកក្នុងករណីដែលអ្នកមានសិទ្ធិលើភាគបម្រុងមានច្រើននាក់អ្នកមានសិទ្ធិលើភាគបម្រុងម្នាក់ៗអាចទទួលភាគបម្រុងតាមសមាមាត្រនៃចំណែកមត៌កបាន។ [40]

ឧទាហរណ៍ ករណីដែលសន្តតិជនមាន សហព័ទ្ធ និងកូនពីរនាក់។ សមាមាត្រនៃភាគបម្រុងរបស់បុគ្គលម្នាក់ៗ ១/២ x ១/៣ =១/៦ នៃទ្រព្យសម្បត្តិរបស់មតកជន។

### ១.៣.២ ការកាត់បន្ថយបង្គ្រប់ភាគបម្រុង

ដើម្បីគណនាទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង មិនមែនមានតែមត៌កប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ ត្រូវបូកទ្រព្យសម្បត្តិសកម្ម ដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម និងទឹកប្រាក់នៃផលប្រយោជន៍ពិសេស [41] ហើយនិងទឹកប្រាក់នៃទ្រព្យមួយចំនួននៃប្រទានកម្មនាពេលនៅរស់ [42] ជាពិសេសដកនឹងបំណុល។ ទ្រព្យដែលជាកម្មវត្ថុនៃការការបន្ថយនូវភាគបម្រុងមាន អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ផលប្រយោជន៍ពិសេស និងប្រទានកម្មមួយចំនួននាពេលនៅរស់។[43] ក្នុងករណីដែលមានការបំពាននូវភាគបម្រុង តាមរយៈសកម្មភាពទាំងនេះ របបភាគបម្រុងបានធានានូវភាគបម្រុង តាមរយៈការបដិសេធនូវអានុភាពនៃសកម្មភាពទាំងនេះ។ ការបន្ថយភាគបម្រុង គឺជាការដែលអ្នកមានសិទ្ធិលើភាគបម្រុង (ព្រមទាំងអ្នកទទួលបន្តនោះ) ទាមទារឲ្យកាត់បន្ថយនូវអច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ផលប្រយោជន៍ពិសេស និងប្រទានកម្មមួយចំនួននាពេលនៅរស់ ចំពោះអ្នកដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ ដែលជាកម្មវត្ថុនៃការកាត់បន្ថយភាគបម្រុង ហើយអានុភាពនឹងកើត

[40] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៣០។
[41] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៣។
[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៣២។
[43] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៣៣។

ឡើងតាមរយៈការទាមទារនេះ។ សិទ្ធិទាមទារឲ្យកាត់បន្ថយភាគបម្រុង ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ឆ្នាំ បានកន្លងហួសគិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុង បានដឹងអំពីការចាត់ផ្តើមសន្តតិកម្ម និងការកំណត់ចំណែកមតិក អច្ច័យទាន ប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ដែលត្រូវបន្ថយភាគបម្រុង។ ម្យ៉ាងទៀតសិទ្ធិទាមទារឲ្យកាត់បន្ថយភាគបម្រុង ក៏ត្រូវរលត់ដោយអាជ្ញាយុកាលបើអំឡុងពេល ៥ឆ្នាំ បានកន្លងហួសគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម។[44] ឧទាហរណ៍ខាងក្រោយបង្ហាញពី ការកាត់បន្ថយភាគបម្រុង។

ឧទាហរណ៍៖ សន្តតិជនគឺមាន ក,ខ,គ សុទ្ធតែកូនរបស់មតកជនទាំងអស់។ មតកជនបានទទួលមរណភាពនៅថ្ងៃទី ១៩/១១/២០១០។ នៅថ្ងៃទី ២២/១១/២០០៩ មតកជនបានធ្វើប្រទានកម្មដីមួយដុំដែលមានតម្លៃ ១៥០,០០០ ដុល្លារទៅឲ្យ ក។ មតកជនពុំមានសន្តតិកម្មអ្វីទេ ទាំងទ្រព្យអកម្ម និងទ្រព្យសកម្ម។ នៅថ្ងៃទី ២៤/០៤/២០១១ ខបានដាក់ពាក្យបណ្តឹងបង្ហាញឆន្ទៈទាមទារឲ្យកាត់បន្ថយភាគបម្រុង ចំពោះ ក។ ចំណែក គ បានដឹងអំពីការដែលមតកជនបានធ្វើប្រទានកម្មចំពោះក ប៉ុន្តែ គ មិនបានទាមទារឲ្យកាត់បន្ថយភាគបម្រុងនេះទេ។

ទ្រព្យសម្បត្តិដែលជាមូលដ្ឋាននៃការគណនា

ទ្រព្យសម្បត្តិសកម្មពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស + ប្រទានកម្មកំណត់មួយពេលនៅរស់ - បំណុល

ជាលេខ៖ 0 + ១៥០,០០០ + 0 – 0 = ១៥០,០០០ ដុល្លារ

ចំនួនទឹកប្រាក់នៃភាគបម្រុងរបស់ ខ = ទ្រព្យសម្បត្តិដែលជាមូលដ្ឋាន X សមាមាត្រនៃភាគបម្រុង

ជាលេខ: ១៥០,០០០ x ១ភាគ២ x ១ភាគ៣ = ២៥,០០០ ដុល្លារ

ចំនួនទឹកប្រាក់ដែលបានបំពានភាគបម្រុង : ចំនួនទឹកប្រាក់នៃភាគបម្រុង - ចំនួនទឹកប្រាក់សរុបដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានតាមរយៈសន្តតិកម្ម - ចំនួនទឹកប្រាក់នៃផលប្រយោជន៍ពិសេស + បំណុលដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកតាមរយៈសន្តតិកម្ម

[44]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៤៥។

ជាលេខ: ២៥,000-0-0+0 = ២៥,000 ដុល្លារ

តាមសមាមាត្រ ២៥,000/១៥0,000 = ១/៦ គឺជាចំណែកដែលត្រូវធ្លាក់ទៅលើ ខ។

## ១.៤ ការយល់ព្រម និងការបោះបង់សន្តតិកម្ម

ការយល់ព្រម និងការបោះបង់សន្តតិកម្មវាជាចំណុចសំខាន់ទាក់ទងនឹងទ្រព្យអកម្មព្រោះថាការយល់ព្រម និងការបោះបង់សន្តតិកម្មដើរតួរសំខាន់ក្នុងការការពារប្រយោជន៍របស់សន្តតិជនដើម្បីកុំឲ្យសន្តតិជនព្រោះតែទទួលសន្តតិកម្មត្រូវធនក្ស័យ ដោយមូលហេតុថា មតកជនមានបំណុលច្រើនជាងទ្រព្យសកម្ម ការប្រើវិធីនេះដើម្បីជៀសវាងនូវការទទួលបន្តនូវបំណុល។ នេះក៏ជាហេតុនាំឲ្យក្រមរដ្ឋប្បវេណីជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវិត្តព្រោះថាច្បាប់មានគោលបំណងដើម្បីការពារសន្តតិជន ហើយគោលការណ៍ទទួលបន្តដោយស្វ័យប្រវិត្តគឺជា គោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិ និងករណីយកិច្ចទាំងអស់របស់មតកជន។ គោលការណ៍នេះប្រសិនបើ មតកជនបន្សល់ទុកនូវកាតព្វកិច្ចច្រើនពេក សន្តតិជនទទួលបន្តនូវកាតព្វកិច្ចទាំងនោះ នឹងធ្វើឲ្យខូចប្រយោជន៍ធ្ងន់ធ្ងរដោយសារសន្តតិកម្ម មូលហេតុនេះដែលនាំក្រមរដ្ឋប្បវេណីកម្ពុជាបង្កើតឲ្យមានរបបបោះបង់នូវសន្តតិកម្ម ឬ ការយល់ព្រមដោយកម្រិត ដើម្បីជៀសវាងនូវស្ថានភាពនេះ។

### ១.៤.១ ការយល់ព្រមទាំងស្រុង និងដោយកម្រិត

ក្រមរដ្ឋប្បវេណីកម្ពុជាការពារប្រយោជន៍សន្តតិជនគួរឲ្យកត់សម្គាល់។ ការយល់ព្រមទាំងស្រុង និងការយល់ព្រមដោយកម្រិតពេលដែលសន្តតិកម្មត្រូវបានចាប់ផ្តើមអនុវត្តច្បាប់អនុញ្ញាតឲ្យសន្តតិជនសម្រេចចិត្តយល់ព្រមទទួលសន្តតិកម្ម ឬ បោះបង់សន្តតិកម្ម ហើយបើមានការយល់ព្រមក្នុងនោះមានពីររបៀបគឺ ការយល់ព្រមទាំងស្រុង និងការយល់ព្រមដោយកម្រិត។ បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ។[45] មានន័យថាសន្តតិជនត្រូវទទួលទាំងស្រុងនូវទ្រព្យសកម្ម និងទ្រព្យអកម្ម។

ការយល់ដឹងពីការយល់ព្រមទាំងស្រុងនៃសន្តតិកម្មមានសារៈសំខាន់សម្រាប់សន្តតិជនក្នុងការបែងចែកសន្តតិកម្ម។ ការយល់ព្រមទាំងស្រុង សន្តតិជនគ្រាន់តែបង្ហាញឆន្ទៈដោយមិនចាំបាច់ដាក់

[45] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៥៤។

ពាក្យសុំទៅតុលាការ វាផ្ទុយពីការយល់ព្រមដោយកម្រិត និងការបោះបង់សន្តតិកម្ម។ ម្យ៉ាងវិញទៀត ត្រូវចាត់ទុកជាការយល់ព្រមទាំងស្រុងដែរ ប្រសិនបើសន្តតិជន បានចាត់ចែងមតិកនោះទាំងអស់ ឬ មួយភាគ លើកលែងតែសកម្មភាពរក្សា ឬ គ្រប់គ្រង ហើយសន្តតិជនមិនបានបង្ហាញឆន្ទៈយល់ព្រម ឬ បោះបង់ក្នុងអំឡុងពេល បីខែគិតចាប់ពីពេលដែលសន្តតិជនបានដឹងថា សន្តតិកម្មកើតឡើងចំពោះខ្លួន លើកលែងតែមានពាក្យសុំពន្យាពេលទៅតុលាការ។

ចំណែកឯការយល់ព្រមដោយកម្រិត គឺជាការយល់ព្រមដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជន បានត្រឹមកម្រិតនៃទ្រព្យសម្បត្តិសកម្មដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម។ វាដូចជាលក្ខណៈការទូទាត់បំណុល ប៉ុន្តែទាល់តែសន្តតិជនទាំងអស់គ្នា បានធ្វើរួមគ្នាទើបអាចធ្វើទៅបាន។[46] សន្តតិជនក្លាយទៅកូនបំណុល ដោយទទួលសន្តតិកម្មនូវកាតព្វកិច្ចទាំងអស់របស់មតកជនក៏ប៉ុន្តែ សន្តតិជនអាចកម្រិតការទទួលខុសត្រូវសង ត្រឹមតែកម្រិតនៃមតិកដែលបានទទួលដោយសន្តតិកម្មបាន។ ម្យ៉ាងវិញទៀតសន្តតិជនដែលធ្វើការយល់ព្រមដោយកម្រិត ត្រូវជូនដំណឹងជាសាធារណៈ ក្នុងអំឡុងពេល ៥ ថ្ងៃបន្ទាប់ពីបានយល់ព្រមដោយកម្រិតហើយ ប្រសិនបើម្ចាស់បំណុលមិនបានស្នើសុំទេ ត្រូវដកឈ្មោះអ្នកនោះចេញពីការជម្រះមតិក។[47] ប៉ុន្តែវិធាននេះអនុវត្តចំពោះតែម្ចាស់បំណុលធម្មតា ចំណែកម្ចាស់បំណុលដែលភ្ជាប់នូវសិទ្ធិប្រាតិភោគប្រត្យក្សដូចជា ហ៊ីប៉ូតែក សិទ្ធិនោះមិនអាចរលត់បានទេ។

ជាទូទៅគោលការណ៍នៃការសង ក្នុងករណីដែលមានការយល់ព្រមដោយកម្រិត ម្ចាស់បំណុលដែលត្រូវសងមុនគេគឺ ម្ចាស់បំណុលដែលសិទ្ធិអាទិភាព បន្ទាប់មកម្ចាស់បំណុលដែលបានដាក់ពាក្យស្នើសុំនៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ បន្ទាប់មកទៀតអច្ច័យលាភីដែលបានដាក់ពាក្យស្នើសុំនៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ ចុងក្រោយម្ចាស់បំណុល និងអច្ច័យលាភីដែលមិនបានស្នើសុំនៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ។

### ១.៤.២ ការបោះបង់សន្តតិកម្ម

ការបោះបង់សន្តតិកម្ម សន្តតិជនមិនទាក់ទងនឹងសន្តតិកម្ម។ ប្រសិនបើមានការយល់ព្រមដោយកម្រិតហើយ ហេតុអ្វីបានជាចាំបាច់មានការបោះបង់សន្តតិកម្មទៅវិញ? ការដែលសន្តតិជន

[46] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៥៦។
[47] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៨១។

បោះបង់សន្តតិកម្ម ដូច្នេះបើសន្តតិជនរស់នៅជាមួយមតកជនលើអចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់មតកជននឹងត្រូវបាត់បង់ដោយសារបំណុល។ ការបោះបង់សន្តតិកម្ម សន្តតិជនម្នាក់ៗត្រូវដាក់ពាក្យសុំទៅតុលាការ។ [48] អំឡុងពេល ៣ខែគិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្ដើម ប៉ុន្តែអំឡុងពេលនេះអាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិជនទៅតុលាការ ហើយសន្តតិជនអាចធ្វើការស្រាវជ្រាវមតិកបាននៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្មនេះ។[49] បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថាបុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូង។[50] បើសិនជាសន្តតិជនដែលមានលំដាប់ស្មើគ្នាបានបោះបង់សន្តតិកម្មទាំងអស់គ្នា សន្តតិ-ជននៃលំដាប់បន្ទាប់ត្រូវធ្វើសន្តតិកម្ម។ បន្ថែមពីនេះសន្តតិកម្មជំនួសមិនត្រូវបានកើតឡើងដែរ។

តារាងទី២ ការប្រៀបធៀបរវាង ការយល់ព្រមទាំងស្រុង ការយល់ព្រមដោយកម្រិត និងការបោះបង់

| ការបង្ហាញឆន្ទៈចំពោះសន្តតិកម្ម | បរិយាយ | | | |
|---|---|---|---|---|
| | ការការពារប្រយោជន៍ | ការជូនដំណឹងទៅតុលាការ | បញ្ជីសារពើភ័ណ្ឌ | បុគ្គលបង្ហាញឆន្ទៈ |
| ការយល់ព្រមទាំងស្រុង | តតិយជន (ម្ចាស់បំណុល) | មិនចាំបាច់ | មិនធ្វើ | សន្តតិជនណាម្នាក់ |
| ការយល់ព្រមដោយកម្រិត | សន្តតិជន | ចាំបាច់ | ត្រូវធ្វើ | សហសន្តតិជន |
| ការបោះបង់ | សន្តតិជន | ចាំបាច់ | មិនធ្វើ | សន្តតិជនណាម្នាក់ |

[48] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦០។
[49] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៥៨។
[50] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦១។

# ជំពូកទី ២ ការអនុវត្តនៃសន្តតិកម្ម

បើយោងតាមរបាយការណ៍ស្តីពីសកម្មភាពការងាររបស់សាលាដំបូងរាជធានីភ្នំពេញ គិតចាប់ពីឆ្នាំ ២០០៩ រហូតដល់ឆ្នាំ ២០១៣ រឿងក្តីពាក់ព័ន្ធនឹងការសុំទាមទារមតិក សុំគ្រប់គ្រង សុំបែងចែកមតិកនៅមានកម្រិតទាបនៅឡើយ។ ទាំងនេះដោយសារការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើសន្តតិកម្មនៅមានកម្រិតនៅឡើយ ដោយសារតែប្រជាពលរដ្ឋមិនបានយល់ច្បាស់ពីអ្វីទៅជាសន្តតិ-កម្មក៏ដូចជាការប្រើប្រាស់ពាក្យពេចន៍របស់ច្បាប់មួយចំនួន ដូចជា លិខិតយថាភូត មតិកជនសន្តតិ-កម្មជំនួស ជាដើម។ ប្រសិនបើក្រឡេកមើលស្ថានភាពជីវភាពរស់នៅសព្វថ្ងៃរបស់ប្រជាជន នៅតាមបណ្តាខេត្តមួយចំនួនវិញ ការអនុវត្តសន្តតិកម្មស្ទើរតែមិនមានទាល់តែសោះដោយសារតែប្រជាពលរដ្ឋមិនបានចាប់អារម្មណ៍ទៅលើការបែងចែកទ្រព្យសម្បត្តិ និងមិនបានគិតគូរឲ្យបានវែងឆ្ងាយអំពីបញ្ហាដែលអាចកើតមានដោយសារតែសន្តតិកម្ម ដែលអាចនាំឲ្យមានការបែកបាក់ក្នុងគ្រួសារក៏មាន។ ដោយសារតែបានគិតគូរអំពីបញ្ហាដែលអាចកើតមានឡើងដោយសារតែសន្តតិកម្ម ច្បាប់បានតម្រូវឲ្យមានការបែងចែកសន្តតិកម្មជាពីរប្រភេទ គឺការបែងចែកតាមការស្រុះស្រួលគ្នា និងការបែងចែកតាមផ្លូវតុលាការ។ ម្យ៉ាងវិញទៀតជាគោលការណ៍របស់ក្រមរដ្ឋប្បវេណីកម្ពុជាមុននឹងធ្វើការបែងចែកតាមផ្លូវតុលាការតម្រូវឲ្យសហសន្តតិជនធ្វើការពិភាក្សាជាមួយគ្នាសិន។

## ២.១ ការបែងចែកតាមការស្រុះស្រួលគ្នា

ការបែងចែកតាមការស្រុះស្រួលគ្នាត្រូវការភាគីសំខាន់មួយ ដើរតួជាស្ពានសម្រាប់ឲ្យភាគីវិវាទប្រាស្រ័យទាក់ទង និងចរចាគ្នាឈានទៅដល់ការដោះស្រាយបញ្ហាដែលកើតឡើង។ ជាគោលការ-ណ៍មុននឹងមានការបែងចែកតាមរយៈតុលាការ សហសន្តតិជនត្រូវតែធ្វើការផ្សះផ្សារគ្នាជាមុនសិន។ គួរយល់ដឹងផងដែរថាការបែងចែកតាមរយៈការស្រុះស្រួលគ្នាផ្តល់ភាពងាយស្រួលដល់សហសន្តតិជនមួយចំនួនដូចជា បង្ការកុំឲ្យមានជម្លោះនៅក្នុងគ្រួសារអាចកើតមានឡើងដោយសារតែទ្រព្យបាន ហើយដោយសារតែទ្រព្យនេះដែរបានធ្វើឲ្យបងប្អូនបង្កើតមិនស្គាល់គ្នាបងមិនស្គាល់ប្អូនប្អូនមិនស្គាល់បងហើយអាចឈានទៅដល់ការបែកបាក់ក្នុងគ្រួសារថែមទៀតផង។

ដើម្បីជៀសវាងមានការឈ្លោះគ្នារវាងបងប្អូន សាច់ញាតិ ត្រូវបានកំណត់អំឡុងពេលឲ្យសហ-សន្តតិជនធ្វើការស្រុះស្រួលក្នុងការសម្រួលចំណែកមតិក ព្រោះថាជាបងប្អូនបង្កើតកុំឲ្យមានបញ្ហាជាមួយគ្នាដោយសារតែទ្រព្យសម្បត្តិធ្វើឲ្យមិនអាចរាប់រក ឬ ចងគុំនុំនឹងគ្នា។ ម្យ៉ាងវិញទៀត

ដោយសារតែប្រពៃណីទំនៀមទម្លាប់របស់ខ្មែរ ចេះស្រលាញ់ អត់ឱនឲ្យគ្នា និងចេះដោះស្រាយបញ្ហាដោយសន្តិវិធី គ្រួសារត្រូវចេះស្រលាញ់សាមគ្គីគ្នា ការបែងចែកមតិកតាមរយៈការស្រុះស្រួលគ្នាគឺជាវិធីដែលល្អបំផុតក្នុងការជៀសវាងនូវការបែកបាក់ក្នុងគ្រួសារ និងដើម្បីកុំឲ្យមានការរិះគន់ពីសង្គម។ ការពិភាក្សាបែងចែកមតិកនេះត្រូវធ្វើឡើងក្នុងអំឡុងពេលមួយខែ ក្រោយពេលចាប់ផ្តើមសន្តតិកម្ម។[51] គួរយល់ដឹងថាបានជាទុកអំឡុងពេលមួយក្រោយការចាប់ផ្តើមសន្តតិកម្មគោរពដល់មរណភាពរបស់មតកជន។

ម្យ៉ាងដើម្បីជៀសវាងកុំឲ្យមានពាក្យនិយាយថាមតកជនទទួលមរណភាពមិនទាន់បានប៉ុន្មានផងបងប្អូនក៏ធ្វើការបែងចែកទ្រព្យសម្បត្តិភ្លាម។ នេះជាការបង្ហាញឲ្យឃើញពីការគោរពចំពោះវិញ្ញាណក្ខន្ធមតកជនទើបច្បាប់ត្រូវទុកអំឡុងពេលមួយខែក្រោយការចាប់ផ្តើមសន្តតិកម្ម។ ប្រសិនបើសហសន្តតិជនធ្វើការពិភាក្សាបែងចែកមតិក នៅក្នុងរយៈពេលដែលច្បាប់បានហាមឃាត់ នោះការបែកចែកនោះមិនអាចមានសុពលភាពបានឡើយ។ ក្នុងករណីដែលទ្រព្យនោះជាកសិផលអាចមានការខូចខាតបើទុកចោល ដូច្នេះសហសន្តតិជនអាចធ្វើការលក់បាននៅពេលដែលសន្តតិកម្មបានចាប់ផ្តើម ឬ ក្រោយសន្តតិកម្ម ដោយត្រូវលក់ប្តូរជាប្រាក់ ហើយទឹកប្រាក់ដែលបានមកពីការលក់នេះត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកមតិក។ ម្យ៉ាងវិញទៀតការពិភាក្សាបែងចែកទ្រព្យសម្បត្តិសហសន្តតិជនត្រូវធ្វើការស្រាវជ្រាវរកសន្តតិជន តើមតិកបានទទួលស្គាល់នៅពេលដែលមានជីវិតដែររឺទេ? ឬក៏មតកជនមានកូនដែលមកពីអាពាហ៍ពិពាហ៍មុនឬទេ? ហើយត្រូវកំណត់ឲ្យច្បាស់ថាសហសន្តតិជនណាខ្លះបានយល់ព្រម ឬ បោះបង់សន្តតិកម្ម ទើបការពិភាក្សាក្នុងការបែងចែកមតិកនោះអាច ធ្វើទៅបានដោយមិនមានឧបសគ្គ ឬ ទំនាស់ផ្សេងៗកើតមានឡើង។

ការបែងចែកមតិក តាមរយៈការស្រុះស្រួលនេះមិនចាំបាច់ មានទម្រង់ជាលាយល័ក្ខណ៍អក្សរទេ។[52] ប៉ុន្តែមតិកខ្លះតម្រូវឲ្យមានការធ្វើជាលាយល័ក្ខណ៍អក្សរ ដូចជាការផ្ទេរសិទ្ធិជាដើម តម្រូវឲ្យមានជាលិខិតយថាភូតដែលមានការបញ្ជាក់ពីសារការី។[53] ការបែងចែកមតិកតាមរយៈការស្រុះស្រួលគ្នានេះសហសន្តតិកម្មមិនមែនចេះតែធ្វើការបែងចែកនោះទេ ពោលសំខាន់គឺសហសន្តតិជនធ្វើការបែងចែកដោយពិនិត្យលើប្រភេទ ស្ថានភាព និងលក្ខណៈរបស់វត្ថុ ឬ សិទ្ធិដែលមានក្នុងមតិកនិងស្ថានភាពផ្សេងៗទៀតដូចជា អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត ជាពិសេស ស្ថានភាព

[51] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៦ កថាខណ្ឌទី១។
[52] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៦ កថាខណ្ឌទី២។
[53] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៦។

ជីវភាពរបស់សហសន្តតិជនម្នាក់ៗ។[54] ដោយសារតែច្បាប់បានគិតគូរដល់មតកជនដែលបានទទួលមរណភាពទៅ និងដើម្បីកុំឲ្យមានភាពគ្មានសណ្តាប់ធ្នាប់សាធារណៈក្នុងសង្គមដោយសារតែការដណ្តើមទ្រព្យសម្បត្តិ។ ការបែងចែកមត៌កតាមរយៈការស្រុះស្រួលត្រូវបានបង្កើតឡើងក្នុងគោលបំណងថែរក្សាទំនៀមទម្លាប់ដែលខ្មែរចេះស្រលាញ់ សាមគ្គីគ្នា និងថែរក្សាសណ្តាប់ធ្នាប់សង្គម កុំឲ្យមានភាពរញ៉េរញ៉ៃ បងប្អូនឈ្លោះគ្នា ដោយសារផលប្រយោជន៍ដែលបានមកពីសន្តតិកម្ម។

## ២.២ ការបែងចែកតាមផ្លូវតុលាការ

ប្រជាពលរដ្ឋកម្ពុជាមួយចំនួនមិនមានទម្លាប់បែងចែកទ្រព្យសម្បត្តិតាមផ្លូវតុលាការ។ តើវាជាការមិនបានយល់ដឹងពីច្បាប់ ឬ ក៏យល់ថាបែងចែកតាមស្រុះស្រួលងាយស្រួលជាងការបែងចែកតាមផ្លូវតុលាការ? ការដែលប្រជាជនកម្ពុជាមិនមានទម្លាប់ធ្វើការបែងចែកមត៌កតាមផ្លូវតុលាការនេះ អាចមកពីកត្តាជីវភាពប្រជាជននៅមានកម្រិត។ មួយវិញទៀតប្រជាជនកម្ពុជាមិនមានទម្លាប់បែងចែកទ្រព្យសម្បត្តិតាមផ្លូវតុលាការទេ ដោយសារតែប្រជាពលរដ្ឋខ្លះយល់ថាការបែងចែករបៀបនេះមានលក្ខណៈស្មុគ្រស្មាញ ជាពិសេសត្រូវការចំណាយថវិកា និងខាតពេលវេលា។ ប្រសិនបើយោងតាមរបាយការណ៍ស្តីពីការងារប្រចាំឆ្នាំនីមួយៗរបស់សាលាដំបូងរាជធានីភ្នំពេញ ឃើញថាស្ថិតិបណ្តឹងទាក់ទងនឹងការបែងចែកសន្តតិកម្មនៅមានកម្រិតទាបគួរឲ្យកត់សម្គាល់ បើធៀបទៅនឹងបណ្តឹងលែងលះប្តីប្រពន្ធ។

ជាគោលការណ៍ការបែងចែកមត៌កតាមផ្លូវតុលាការត្រូវបានអនុវត្តនៅពេលដែលសហសន្តតិជនធ្វើការបែងចែកមត៌កដោយការស្រុះស្រួល ឬ ការពិភាក្សាគ្នាមិនបានសម្រេច។ ហេតុនេះតុលាការដើរតួសំខាន់ក្នុងការបែងចែកជំនួសសន្តតិជន។ ការបែងចែកតាមផ្លូវតុលាការនេះមិនអាចធ្វើទៅបានឡើយប្រសិនបើគ្មានពាក្យបណ្តឹងពីសហសន្តតិជនណាម្នាក់ដាក់ពាក្យសុំទាមទារទៅតុលាការឲ្យធ្វើការបែងចែកមត៌ក។

[54] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៧។

តារាងខាងក្រោមប្រៀបធៀបចំនួនសុំណុំរឿងសុំបែងចែកមតិក និងសុំលែងលះ

តារាងទី៣៖ តួលេខសំណុំរឿងសុំបែងចែកមតិក និងសុំលែងលះ

| កាលបរិច្ឆេទ | ប្រភេទរឿងក្តី | ចំនួន |
|---|---|---|
| ១៦/១១/២០១២ - ១៥/១១/២០១៣ | ការសុំបែងចែកមតិក | ៥៤ |
| | ការសុំលែងលះ | ៦៩០ |
| ១៦/១១/២០១១ - ១៥/១១/២០១២ | ការសុំបែងចែកមតិក | ៥៥ |
| | ការសុំលែងលះ | ៩៦០ |
| ១៦/១១/២០១០ - ១៥/១១/២០១១ | ការសុំបែងចែកមតិក | ៤៩ |
| | ការសុំលែងលះ | ៨៤៩ |
| ១៦/១១/២០០៩ - ១៥/១១/២០១០ | ការសុំបែងចែកមតិក | ៤៥ |
| | ការសុំលែងលះ | ៧០៨ |

(ប្រភព៖ របាយការណ៍ស្តីពីសកម្មភាពការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជ-ធានីភ្នំពេញ ពីឆ្នាំ២០០៩ រហូតដល់ឆ្នាំ ២០១៣)

តុលាការធ្វើការបែងចែកមតិកយ៉ាងដូចម្តេចដើម្បីឲ្យសហាសន្តតិជនសុខចិត្តទទួលតាមការបែងចែក។ ចំពោះការបែងចែកមតិក ជាដំបូងតុលាការត្រូវពិចារណាទៅលើទំនៀមទម្លាប់ក្នុងតំបន់ជាមុនសិន ពោលគឺតុលាការមិនត្រូវធ្វើការបែងចែកដោយលម្អៀង ដែលអាចប៉ះពាល់ដល់ទំនៀមទម្លាប់ប្រពៃណីល្អរបស់ខ្មែរ។ ម្យ៉ាងវិញទៀតតុលាការត្រូវគោរពតាមមតិភាគច្រើនរបស់សហាសន្តតិជន ប៉ុន្តែបើមតិភាគច្រើននោះមិនសម្បូរម្យទេ តុលាការត្រូវពិចារណាលើមតិភាគតិច ឬ ក៏ព្យាយាមស្វែងរកនីតិវិធីណាមួយដែលអាចឲ្យសហាសន្តតិជនទទួលយកការសម្រេចរបស់តុលាការ។ ហើយការបែងចែកមតិកនេះ ក៏ដូចជាការបែងចែកតាមរយៈការស្រុះស្រួលគ្នាដែរ ដោយតុលាការត្រូវ

ពិនិត្យលើប្រភេទស្ថានភាពលក្ខណៈរបស់វត្ថុ និងស្ថានភាពផ្សេងៗទៀតដូចជា អាយុ មុខរបរ ស្ថានភាពផ្លូវកាយ ផ្លូវចិត្ត និងស្ថានភាពជីវភាពរបស់សហសន្តតិជនម្នាក់ៗ។ ចំពោះទ្រព្យដែលមិនអាចធ្វើការបែងចែកបាន តុលាការអាចលក់បានដោយយកប្រាក់ដែលបានពីការលក់នោះជាកម្មវត្ថុក្នុងការបែងចែកមត៌ក។

សិទ្ធិលើបំណុលក៏អាចចាត់ទុកជាកម្មវត្ថុនៃការបែងចែកមត៌កបានដែរ ប៉ុន្តែសិទ្ធិលើបំណុលត្រូវធ្វើជាលិខិតយថាភូត ហើយសហសន្តតិជនត្រូវតែបង្ហាញលិខិតនេះជូនទៅតុលាការដើម្បីធ្វើការពិនិត្យ និងបែងចែកទៅតាមចំណែករបស់សហសន្តតិជន។[55] ប្រសិនបើសិទ្ធិលើបំណុលមិនបានធ្វើជាលិខិតយថាភូតនោះទេសិទ្ធិលើបំណុលមិនអាចធ្វើការតតាំងជាមួយនឹងកូនបំណុលបានឡើយ។ ម្យ៉ាងវិញទៀត សហសន្តតិជនត្រូវទទួលខុសត្រូវទៅតាមសមាមាត្រនៃចំណែកមត៌ក។

គួរកត់សម្គាល់ដែរថាការស្រាវជ្រាវរកសន្តតិជនមានសារៈសំខាន់ណាស់ក្នុងការបែងចែកមត៌ក។ នៅពេលដែលធ្វើការបែងចែកមត៌កសហសន្តតិជនត្រូវធ្វើការស្វែងរក ឬ ស្រាវជ្រាវឲ្យបានច្បាស់ថាមត៌កបានទទួលស្គាល់កូននៅពេលដែលនៅមានជីវិតដែររឺទេ ឬ ក៏សហសន្តតិជនមិនត្រូវធ្វើការលាក់បាំងថាគ្មាន សន្តតិជនផ្សេងឡើយ ដោយសារតែសន្តតិជននោះ ជាបងប្អូនម្តាយ ឬ ឪពុកទីទៃ ឬ ធ្វើការហាមឃាត់មិនឲ្យសន្តតិជននោះចូលរួមក្នុងការបែងចែកមត៌ក។ ប្រសិនបើមានករណីនេះកើតមានឡើងក្រោយពេលដែលធ្វើការបែងចែកមត៌ករួចរាល់ ហើយនោះ ការបែងចែកនោះត្រូវចាត់ទុកជាមោឃៈ។ [56] ចុះប្រសិនបើជនដែលទទួលស្គាល់ជាសន្តតិជនបានដឹងក្រោយពេលដែលការបែងចែកមត៌កមានសុពលភាព ឬ ហួសអំឡុងពេលដែលបានកំណត់ដោយច្បាប់ឲ្យធ្វើការតវ៉ាសាជាថ្មី? ក្នុងករណីនេះជនដែលបានទទួលស្គាល់ជាសន្តតិជនបានដឹងអំពីការចែកមត៌កក្រោយអំឡុងពេលដែលច្បាប់បានកំណត់នោះសន្តតិជនមិនមានសិទ្ធិទាមទារតវ៉ាឲ្យធ្វើការបែងចែកមត៌កសាជាថ្មីបានឡើយ។

[55]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧៥។
[56]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧៤។

# ជំពូកទី ៣ បញ្ហាប្រឈមនៃសន្តតិកម្ម

បញ្ហាប្រឈមនៃសន្តតិកម្មមានការកើតឡើងគួរឲ្យកត់សម្គាល់។ ជាធម្មតាទោះបីសន្តតិកម្មបានធ្វើការបែងចែកតាមការស្រុះស្រួលគ្នា និងធ្វើការបែងចែកតាមផ្លូវតុលាការក៏ដោយ ក៏បញ្ហាប្រឈមនៅតែអាចកើតមានឡើង ព្រោះតែទំនាស់ផលប្រយោជន៍ដែលនាំឲ្យមានការអាក់អន់ស្រពោនចិត្តនឹងគ្នារវាងសហសន្តតិជន។ ជាទូទៅទំនាស់ផលប្រយោជន៍កើតមានឡើងដោយសារតែមានការពាក់ព័ន្ធជាមួយនឹងទ្រព្យសម្បត្តិ។

## ៣.១ នីតិវិធីក្នុងការបែងចែកសន្តតិកម្ម

ការបែងចែកសន្តតិកម្មមានផលលំបាកដល់សន្តតិជន។ ដោយមូលហេតុថាអាជ្ញាធរនៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ មិនព្រមធ្វើការផ្ទេរសិទ្ធិកម្មសិទ្ធិ ទៅឲ្យសាច់ញាតិរបស់មតកជនទេ ហើយបញ្ជាក់មូលហេតុថាទាល់តែមានសាលក្រមពីតុលាការទើបអាជ្ញាធរព្រមផ្ទេរកម្មសិទ្ធិទៅឲ្យគាត់ ទោះបីជាមតកជនមានកូនតែម្នាក់ ហើយសហព័ទ្ធបានលែងលះគ្នាស្របច្បាប់ ឬទទួលមរណភាពក៏ដោយ។ បន្ថែមពីនេះទៀតបើកូនទាំងអស់បានព្រមឯកភាពគ្នា ហេតុអ្វីមិនចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យ? តើការមិនព្រមផ្ទេរឲ្យមានច្បាប់ចែង ឬ យ៉ាងណា?[57] ការទាមទារសេចក្តីសម្រេចតុលាការពីអាជ្ញាធរសុរិយោដី តើមានគុណវិបត្តិនិងគុណសម្បត្តិអ្វីខ្លះ?

ជាក់ស្តែងការទាមទារសេចក្តីសម្រេចពីតុលាការជាការត្រឹមត្រូវ ព្រោះថាសន្តតិជនដែលចង់ផ្ទេរកម្មសិទ្ធិឯកជន ត្រូវមានលិខិតយថាភូតដើម្បីផ្ទេរកម្មសិទ្ធិពីមតកជនមកខ្លួនផ្ទាល់ ការធ្វើបែបនេះវាជាការល្អ ប៉ុន្តែសន្តតិជនអាចខាតប្រយោជន៍ច្រើនដោយហេតុថា ត្រូវចំណាយពេលវេលាដើម្បីរង់ចាំសេចក្តីសម្រេចពីតុលាការទើបអាចមកមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បន្ថែមពីនេះប្រសិនសន្តតិជនមិនយល់ពីច្បាប់ត្រូវ ជួលមេធាវី ឬ ជួលអ្នករត់ការដើម្បីធ្វើការនេះ ដូចនេះត្រូវចំណាយទាំងពេលវេលា និងថវិកា។ ផ្ទុយទៅវិញមន្ទីរធ្វើបែបដោយសារតែមានជំនឿទុកចិត្តលើសេចក្តីសម្រេចរបស់តុលាការ ព្រោះមន្ទីរធ្វើការផ្ទេរកម្មសិទ្ធិផ្អែកលើសេចក្តីសម្រេចរបស់តុលា-ការដោយមិនចង់ឲ្យមានកំហុសរដ្ឋបាលប្រសិនជាខុសក៏ការទទួលខុសត្រូវរបស់តុលាការដែរ។

បញ្ហាមួយទៀតឪពុកម្តាយលែងលះគ្នាកូនដែលជាអនីតិជន ឬ នីតិជនដែលទៅរស់នៅជាមួយម្តាយ ឬ ឪពុកតែម្ខាងអាចខូចប្រយោជន៍ ព្រោះថាបើប្រសិនកូនទៅរស់នៅជាមួយម្តាយ កាលដែលឪពុក

---

[57] ហេង សុធា (មេធាវី នៅការិយាល័យ ការពារសិទ្ធិ), បទសម្ភាសដោយ ហេង ច័ន្ទសុត្រា, ០៧ ឧសភា ២០១៤។

ទៅយកប្រពន្ធមួយថ្មីទៀត ពេលឪពុកនោះស្លាប់ ប្រពន្ធថ្មីអាចនឹងលាក់ទ្រព្យសម្បត្តិដើម្បីកុំឲ្យកូនដើមទទួលបាន។ ហេតុនេះតុលាការត្រូវស្វែងរកយ៉ាងលម្អិតអំពីបញ្ហានេះ តុលាការត្រូវការការបញ្ជាក់ពីមេភូមិ ឬ ចៅសង្កាត់ឲ្យច្បាស់។

## ៣.២ ដីមិនទាន់បានចុះបញ្ជី

គួរកត់សម្គាល់ផងដែរថា ប្រសិនបើដីមិនទាន់បានចុះបញ្ជីក៏ជាចំនុចសំខាន់នៃការពិភាក្សា។ ដីដែលមិនទាន់បានចុះបញ្ជីពិបាកក្នុងការបែងចែក។ ទ្រព្យសម្បត្តិនោះត្រូវមានចំណែករបស់សន្តតិជននីមួយៗ ដែលជាចំណែកនៃទ្រព្យអវិភាគវាពិបាកថា នឹងត្រូវដាក់ឈ្មោះសន្តតិជនណា ហេតុនេះចាំបាច់ត្រូវមានការធ្វើកិច្ចព្រមព្រៀងរវាងសន្តតិជន និងសន្តតិជន ដោយព្រមរកសន្តតិជនណាម្នាក់តំណាងអ្នកទាំងអស់នោះ ទើបទ្រព្យសម្បត្តិនោះងាយស្រួលក្នុងចាត់ចែង។ ប្រសិនបើដីមិនទាន់ចុះបញ្ជី ធ្វើឲ្យខូចប្រយោជន៍ដល់រដ្ឋ ព្រោះមិនបានផ្ទេរកម្មសិទ្ធិនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋខាតបង់ពន្ធដែលបានពីការផ្ទេរកម្មសិទ្ធិនេះ។ ស្ថិតិនៃការចុះបញ្ជីតាំងពីចាប់ផ្តើមរហូតដល់ខែ ឧសភា និងមេសាគិតត្រឹមឆ្នាំ ២០១២ ការបន្តមតិក មានចំនួន ០។[58]

ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៣ មានលេចចេញប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រាមួយគួរឲ្យកត់សម្គាល់។ ប្រកាសស្តីពី ការប្រមូលពន្ធប្រថាប់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុគ្រោះពន្ធ ចំពោះពន្ធប្រថាប់ត្រារបស់សន្តតិកម្ម និងប្រទានកម្ម។ ចំពោះការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យពីញាតិ ត្រូវបានអនុគ្រោះពន្ធប្រថាប់ត្រាដែលអនុញ្ញាតឲ្យដកចេញពីតម្លៃជាមូលដ្ឋានគិតពន្ធចំនួនៈ ២០០.០០០.០០០ លានរៀល ចំពោះសន្តតិកម្ម រីឯប្រទានកម្មវិញ ១០០.០០០.០០០ លានរៀល។[59]

រដ្ឋបានលើកទឹកចិត្តប្រជាពលរដ្ឋដើម្បីចុះបញ្ជីដោយអនុគ្រោះពន្ធដើម្បីជំរុញឲ្យមានការចុះបញ្ជី ប៉ុន្តែការអនុគ្រោះពន្ធនេះ រដ្ឋក៏ខាតបង់ច្រើនដែរ ដោយហេតុថា ត្រូវដកចេញពីតម្លៃ ពីរលានរៀលចំពោះសន្តតិកម្ម។ ការដកនេះមានតម្លៃច្រើនគួរសម រដ្ឋបានចំណូលតិចដោយសារការជំរុញឲ្យប្រជាពលរដ្ឋចុះបញ្ជីសន្តតិកម្ម។

---

[58] របាយការណ៍ស្តីពី លទ្ធផលសរុបនៃការចុះបញ្ជីដីធ្លី ចាប់តាំងពីថ្ងៃចាប់ផ្តើមរហូតដល់ខែឧសភា ឆ្នាំ ២០១២។

[59] ប្រកាសស្តីពី ការប្រមូលពន្ធប្រថាប់ត្រា, លេខ៧៣៥សហវ/ប្រក/អពជ, ០៨ សីហា ២០១៣, ប្រការ៥ ចំណុច ខ។

# សេចក្តីសន្និដ្ឋាន

សន្តតិកម្មការពារប្រយោជន៍របស់សន្តតិជន និងតតិយជនចំពោះលើបំណុល។ ប្រសិនបើទ្រព្យអកម្មមានចំនួនច្រើនជាងទ្រព្យសកម្មនោះ សន្តតិជនបង្ហាញឆន្ទៈយល់ព្រម ដោយមានកម្រិត ឬ ធ្វើការបោះបង់សន្តតិកម្ម។ ប៉ុន្តែសន្តតិកម្មក៏បានការពារដល់តតិយជនដែរ ទោះបីជាមតកជនបានទទួលមរណៈភាពក៏ដោយ ក៏មិនអាចរួចផុតពីបំណុលដែលជំពាក់ម្ចាស់បំណុលដែរ ដោយសន្តតិជនជាអ្នកទទួលខុសត្រូវលើបំណុលនេះ។ ប្រសិនបើសន្តតិជន ធ្វើការបង្ហាញឆន្ទៈបោះបង់សន្តតិកម្ម នោះទ្រព្យសម្បត្តិរបស់មតកជនត្រូវដាក់លក់ឡៃឡុង ដើម្បីសងបំណុលដល់ម្ចាស់បំណុល។

ការសម្រួលចំណែកមតិកបានការពារផលប្រយោជន៍របស់សហសន្តតិជន ដោយការសម្រួលចំណែកមតិកនេះត្រូវធ្វើឡើងសមភាពរវាងសហសន្តតិជន។ ក្នុងករណីដែល សន្តតិជនណាម្នាក់បានទទួលផលប្រយោជន៍ពិសេស ដូចជាប្រទានកម្ម និងអច្ច័យទានមុន ពេលដែលសន្តតិកម្មបានចាប់ផ្តើម ទ្រព្យទាំងនោះត្រូវធ្វើការគណនាបញ្ចូលគ្នាជាមួយមតិក ដើម្បីធ្វើការសម្រួលចំណែកមតិកទៅសហសន្តតិជនម្នាក់ៗ។

ផលប្រយោជន៍មួយចំនួនរបស់សន្តតិជនត្រូវបានការពារតាមរយៈភាគបម្រុង។ មតកសាសន៍ត្រូវធ្វើឡើងតាមឆន្ទៈរបស់មតកជន ប៉ុន្តែច្បាប់មិនអនុញ្ញាតឲ្យតតិយជនទទួលបានចំណែកទ្រព្យសម្បត្តិទាំងអស់ ហើយមិនគិតពីសន្តតិជនឡើយ ទោះបីជាមតកជនបានបង្ហាញឆន្ទៈបែបនេះក៏ដោយ។

រីឯការបែងចែកសន្តតិកម្មវិញ សហសន្តតិជនត្រូវធ្វើការសម្រុះសម្រួលគ្នាជាមុនសិនមុននឹងឆ្លងនីតិវិធីបែងចែកតាមផ្លូវតុលាការ។ ទំនាស់អាចកើតមានឡើងរវាងសហសន្តតិជន នៅពេលដែលការសម្រុះសម្រួលមិនអាចសម្រេចទៅបានដោយជោគជ័យដែលជាហេតុនាំ ឲ្យការដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីធ្វើការបែងចែកទ្រព្យសម្បត្តិ។ តុលាការធ្វើការបែង ចែកទ្រព្យដោយស្មើភាពរវាងសហសន្តតិជន។

បញ្ហាមួយចំនួននៅតែលេចឡើងពាក់ព័ន្ធនឹងសន្តតិកម្ម ដូចជានិតីវិធីក្នុងការបែងចែក សន្តតិ-កម្ម និងទ្រព្យដែលមិនបានចុះបញ្ជីជាដើម។ ចំពោះនិតីវិធីក្នុងការបែងចែកសន្តតិកម្ម មានលក្ខណៈស្មុគស្មាញដល់សន្តតិជន ក្នុងការផ្ទេរកម្មសិទ្ធិលើអចលទ្រព្យ។ សន្តតិជនត្រូវតែ សាលក្រមបញ្ជាក់ពីតុលាការ ដើម្បីបញ្ជាក់ថាពិតជាសន្តតិជនពិតប្រាកដមែន។ និតីវិធីនេះធ្វើឲ្យសន្តតិជនមានការខាតបង់ថវិកា និងពេលវេលា។ រីឯដីដែលមិនទាន់ចុះបញ្ជី រដ្ឋបានបន្ធូរបន្ថយពន្ធ ដើម្បីឲ្យប្រជាពលរដ្ឋបានចុះបញ្ជីដើម្បីលើកជំរុញឲ្យការប្រមូលពន្ធលើការផ្ទេរមតិក។

# អនុសាសន៍

រាជរដ្ឋាភិបាលគួរតែណែនាំដល់ក្រសួងពាក់ព័ន្ធនានាដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋ ក៏ដូចជាការអភិវឌ្ឍប្រទេសផងដែរ។ ដើម្បីឲ្យមានការរីកចំរើនថែមទៀតសូមឲ្យ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវពង្រឹងដល់មន្ត្រីនគរបាល និងតុលាការឱ្យសហការគ្នាឱ្យបានល្អក្នុងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវទៅតាមសមត្ថកិច្ច និងតួនាទីដែលបានកំណត់ក្នុងនីតិវិធីច្បាប់ជាធរមាន ដើម្បីធានាក្នុងការស្វែងរកយុត្តិធម៌ជូនភាគី។ ក្រសួងយុត្តិធម៌ត្រូវបង្កើនការផ្សព្វផ្សាយឲ្យដូចជាការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ សូមឲ្យក្រសួងយុត្តិធម៌បង្កើតការផ្សព្វផ្សាយក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីថែមទៀត ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងសន្តតិកម្មដល់ចៅក្រម និងមន្ត្រីអនុវត្តច្បាប់ដើម្បីធានានូវភាពយុត្តិធម៌ និងពន្លឿនការដោះស្រាយរឿងក្តីឱ្យបានឆាប់រហ័ស។ ក្រសួងព័ត៌មានត្រូវបង្កើនឲ្យមានការផ្សព្វផ្សាយកម្មវិធីផ្នែកច្បាប់ឲ្យបានច្រើនជាងនេះដែលការផ្សព្វផ្សាយនោះស្តែងតាមរយៈ ទូរទស្សន៍ និងវិទ្យុ ដើម្បីជាជំនួយដល់ការយល់ដឹងរបស់ប្រជាពលរដ្ឋទោះបីជាប្រជាពលរដ្ឋយល់ដឹងមិនស៊ីជំរៅ ក៏អាចឲ្យប្រជាពលរដ្ឋយល់ខ្លះៗដែរ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបង្កើតឲ្យមានការធ្វើឲ្យប្រសើរឡើងថែមទៀតនូវការពន្លឿននីតិវិធីនៃការចុះបញ្ជីសន្តតិកម្ម ដើម្បីការកាត់បន្ថយការចំនាយពេលវេលារបស់ប្រជាពលរដ្ឋចំពោះការរង់ចាំការចុះបញ្ជីផងដែរ។ បន្ថែមពីនេះទៀត រដ្ឋាភិបាលជំរុញឲ្យបានចុះបញ្ជីដីធ្លីឆាប់រហ័ស។

ជាចុងក្រោយសូមឲ្យរាជរដ្ឋាភិបាលគួរតែជំរុញការអភិវឌ្ឍ និងការយកចិត្តទុកដាក់ខ្ពស់ក្នុងវិស័យផ្នែកច្បាប់ ក៏ដូចជាវិស័យសុខាភិបាល និងវិស័យអប់រំ ដើម្បីជាការអភិវឌ្ឍប្រទេសជាតិជាធំជាជាងប្រយោជន៍បុគ្គល បន្ថែមពីលើនេះទៀតវិស័យផ្នែកច្បាប់គឺត្រូវយកចិត្តឲ្យបានខ្ពស់ ខាងវិស័យដីធ្លីជាសំខាន់៕

# គន្ថនិទ្ទេស


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣។

អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។

ក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ ១៨៩៦។

ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

ប្រកាសស្តីពី ការប្រមូលពន្ធប្រថាប់ត្រា, លេខ៧៣៥/សហវ/ប្រក/អពជ, ០៨ សីហា ២០១៣។

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០។

ហាប់ ផល្លី. *"វិធីសាស្ត្រស្រាវជ្រាវ."* មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទ-នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ ២០១៣។

ត្រឹងងា. *ប្រវត្តិសាស្ត្រខ្មែរ.* បោះពុម្ពលើកទី៣. ភ្នំពេញ៖ បណ្ណាគារ IBC, ឆ្នាំ ២០០៩។

សរ សុវណ្ណ. *របាយការណ៍ស្តីពី លទ្ធផលសរុបនៃការចុះបញ្ជីដីធ្លី ចាប់តាំងពីថ្ងៃចាប់ផ្តើមរហូតដល់ខែឧសភា ឆ្នាំ២០១២ របស់រាជធានី/ខេត្ត.* លេខ៨១៩ LASSP ភ្នំពេញ៖ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, ២៩ មិថុនា ២០១២។

ជីវ កេង. *របាយការណ៍ស្តីពីសកម្មភាពការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជ-ធានីភ្នំពេញ.* លេខ០២រប.៩២១.១១. ភ្នំពេញ៖ សាលាដំបូងរាជធានីភ្នំពេញ, ០៤ មករា ២០១១។

ជីវ កេង. *របាយការណ៍ស្តីពីសកម្មភាពការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជ-ធានីភ្នំពេញ.* លេខ២២៤០រប.៩២១.១១. ភ្នំពេញ៖ សាលាដំបូងរាជធានីភ្នំពេញ, ៣០ ធ្នូ ២០១១។

ជីវ កេង. *របាយការណ៍ស្តីពីសកម្មភាពការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជ-ធានីភ្នំពេញ.* លេខ៧៧៤៧រប.៩២១.១២. ភ្នំពេញ៖ សាលាដំបូងរាជធានីភ្នំពេញ, ០៥ ធ្នូ ២០១២។

ជីវ កេង. *របាយការណ៍ស្តីពីសកម្មភាពការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជ-ធានីភ្នំពេញ.* លេខ៩៦៥៧រប.៩២១.១៣. ភ្នំពេញ៖ សាលាដំបូងរាជធានីភ្នំពេញ, ៣១ ធ្នូ ២០១៣។